**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciencess Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ចៅក្រមស៊ើបសួរ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ **លោក នាង ប៉ុកអាយ**

**លោក ហួរ លីហួរ**

សាស្ត្រាចារ្យណែនាំ

លោកសាស្ត្រាចារ្យ **មីន សំអុល**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២១

ឆ្នាំសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **នាង ម៉ុករស្មី** និង **ហួរ លីហួរ** ជានិស្សិត **ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ** ឆ្នាំទី៤ ជំនាន់ទី២១ ក្នុងឆ្នាំសិក្សា២០១៧-២០២១ សូមថ្លែងនូវកតញ្ញូនិងដឹងគុណដ៏ជ្រាលជ្រៅមិនអាចកាត់ថ្លៃបាន ដល់លោកអ្នកមានគុណរបស់យើងខ្ញុំទាំងពីរ ដែលបានផ្តល់កំណើត លះបង់នឹងកម្លាំងកាយចិត្ត ពុះពារគ្រប់ឧបសគ្គ ដល់រូបយើងខ្ញុំទាំងពីរ និងបីបាច់ថែរក្សា ព្រមទាំងបានផ្គត់ផ្គង់ចំពោះការស្នាក់នៅ ការរៀនសូត្រតាំងពីថ្នាក់មតេយ្យសិក្សារហូតដល់កម្រិតបរិញ្ញាបត្រ និងបានរួមចំណែកនូវការផ្តល់កម្លាំងកាយចិត្ត ការអប់រំ ប្រៀនប្រដៅ ព្រមទាំងផ្តល់នូវព្រហ្មវិហារធម៌ ពីសំណាក់បុព្វញាតិ និងសាខាញាតិ។ សេចក្តីដឹងគុណទាំងអស់ពុំអាចកាត់ថ្លៃបាន មិនអាចរៀបរាប់អស់ នៅក្នុងសេចក្តីថ្លែងអំណរគុណនេះអស់បានឡើយ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់នូវកន្លែងបណ្តុះបណ្តាលចំណេះដឹង និងបណ្តុះបណ្តាលនូវស្មារតីការស្រាវជ្រាវ និងការបង្កើនចំណេះវិជ្ជាផ្នែកនីតិសាស្ត្រ រហូតដល់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ប្រកបដោយភាពជោគជ័យ និងគុណភាពនៃចំណេះដឹងពិតប្រាកដ។

យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តម លុយ ចណ្ណា សាកលវិទ្យាធិការ និងលោក-លោកស្រី សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ** ព្រមទាំងលោក-លោកស្រី សាស្ត្រាចារ្យ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់នូវការអប់រំ ព្រមទាំងចំណេះដឹង និងក្រមសីលធម៌ដល់យើងខ្ញុំក្នុងអំឡុងពេល០៤ឆ្នាំនេះ។

ជាងនេះទៅទៀតក៏សូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រងនៃ **បណ្ណាល័យនីតិសាស្ត្រ** បានរៀបចំ និងគ្រប់គ្រងឯកសារ ព្រមទាំងសៀវភៅដែលបង្កជាលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវ និងចូលរួមចំណែកក្នុងការរៀបចំ តាក់តែងជាសារណានេះឡើង។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ លោកសាស្ត្រាចារ្យ **មីន សំអុល** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណានេះ ដែលលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃផ្តល់នូវគំនិតយោបល់ក្នុងការកែសម្រួល និងតម្រង់ផ្លូវដល់យើងខ្ញុំកន្លងមករហូតបានសម្រេចនូវស្នាដៃមួយនេះ។

ជាចុងក្រោយយើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណដល់ បងប្អូននិស្សិតដែលបានស្គាល់ និងបានផ្តល់កម្លាំងចិត្តជំរុញការសរសេរ និងតាក់តែងសារណានេះឡើង ដោយផ្តល់នូវគុណតម្លៃទទួលទុកជាឯកសារស្រាវជ្រាវ ជាបណ្តោះអាសន្ននិងរួមចំណែកជាការផ្តល់គំនិតបន្តិចបន្តួចគ្រាន់ជាការស្រាវជ្រាវបន្ថែមក្នុងថ្នាក់នីតិសាស្ត្រ និងបង្ហាញបទពិសោធន៍ ចំពោះការអនុវត្តជាក់ស្តែង ដើម្បីយកមកប្រៀបធៀបនិងទ្រឹស្តីដែលបានផ្តល់ដោយសាស្ត្រាចារ្យ។

# អារម្ភកថា

សព្វថ្ងៃនេះមានកូនខ្មែរជាច្រើនក្រុមបាននឹងកំពុងខិតខំស្រាវជ្រាវច្បាប់ខ្មែរ ដើម្បីចូលរួមចំណែកក្នុងការកសាងជាតិជាមួយនឹងរាជរដ្ឋាភិបាល។ ក្នុងចំណោមនោះក៏មានពួកយើងដែលជាក្រុមនិស្សិតនៃសាលាច្បាប់បានបបួលគ្នីគ្នា ចាប់ដៃសាមគ្គីគ្នាជាក្រុមដើម្បីសិក្សាស្រាវជ្រាវទៅលើប្រធានបទទាក់ទងទៅនឹងវិស័យច្បាប់នេះផងដែរ។ យើងសង្កេតឃើញថាវិស័យព្រហ្មទណ្ឌនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ព្រោះថាវិស័យនេះគឺពិតជាមានសារៈសំខាន់ជាខ្លាំងព្រោះកាលណាគេនិយាយពាក្យថាព្រហ្មទណ្ឌគឺគេតែងតែនឹកឃើញទៅដល់បទល្មើសទាំងឡាយដែលបានចែងយ៉ាងច្បាស់អំពីមូលទោស ដែលមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ជាអាទិ៍។ ប៉ុន្តែប្រសិនបើគេនិយាយពាក្យថានីតិវិធីព្រហ្មទណ្ឌវិញគឺគេចង់និយាយអំពីដំណើរការប្រព្រឹត្តទៅនៃដំណាក់កាលនៃរឿងក្តីព្រហ្មទណ្ឌដែលដំណាក់កាលនេះមានចំនួនបួនដំណាក់កាលពោលគឺគិតចាប់ពីដំណាក់កាល នគរបាលយុត្តិធម៌ដល់ដំណាក់កាលជំនុំជម្រះនៃដំណើររឿងក្តីព្រហ្មទណ្ឌ។ សារណាបញ្ចប់ការសិក្សាអំពីចៅក្រមស៊ើបសួរនេះ ត្រូវបានបំពេញទៅតាមតម្រូវការរបស់សាកលវិទ្យាល័យក៏ដូចជាមានការស្រឡាញ់ពេញចិត្តទៅលើវិស័យព្រហ្មទណ្ឌ ពីសំណាក់ពួកយើងដែលជានិស្សិតផ្ទាល់ទើបពួកយើងសម្រេចចិត្តថានឹងជ្រើសរើសយកប្រធានបទចៅក្រមស៊ើបសួរនេះមកធ្វើជាសារណា ដើម្បីឱ្យមានការស៊ីជម្រៅចំពោះចំណេះដឹងផ្នែកនីតិវិធីព្រហ្មទណ្ឌក្នុងដំណាក់កាលនៃការស៊ើបសួរនេះ ក៏ដូចជាធ្វើសារណាបញ្ចប់ឆ្នាំសិក្សា។កិច្ចការស្រាវជ្រាវនេះផងដែរជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងដោយពឹងផ្អែកទៅលើទ្រឹស្តីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ដូចជាច្បាប់ពិសេសនានាពាក់ទៅនឹងចៅក្រមស៊ើបសួរ មិនតែប៉ុណ្ណោះទ្រឹស្តីទាំងនេះគឺយើងនឹងលើកយកតែច្បាប់ដែលចូលជាធរមាននៅពេលបច្ចុប្បន្ននេះតែប៉ុណ្ណោះ ពោលគឺក្រមនីតិវិធីព្រហ្មទណ្ឌអន្តរកាលគឺពួកយើងមិនបានយកបញ្ចូលនៅក្នុងសារណានេះឡើយ។ ពិសេសជាងនេះទៅទៀតនោះ ដើម្បីឱ្យការស្រាវជ្រាវមួយនេះទៅមុខយ៉ាងរលូននិងច្បាស់លាស់នោះពួកយើងដែលជានិស្សិតច្បាប់ដែលរួមមានខ្ញុំបាទ នាង ប៉ុកអាយ និងលោក ហូរ លីហួរ បានសម្រេចចិត្តថាធ្វើការជ្រើសរើសលោកសាស្ត្រាចារ្យ មីន សំអុល ដែលជាសាស្ត្រាចារ្យធ្លាប់បានបង្រៀនពួកយើងក្នុងវិស័យព្រហ្មទណ្ឌមកដឹកនាំប្រធានបទមួយដែលទាក់ទងទៅ នឹង នីតិវិធីក្នុងរឿងព្រហ្មទណ្ឌគឺ ដំណាក់កាលចៅក្រមស៊ើបសួរ ពោលគឺជាដំណាក់កាលទី៣ក្នុងដំណើរនៃកិច្ចនីតិវិធីព្រហ្មទណ្ឌដើម្បីធ្វើការដឹកនាំពួកយើងក្នុងកិច្ចការមួយនេះផងដែរ។ ហើយក្នុងនាមយើងជានិស្សិត ក៏ដូចជាសាស្ត្រាចារ្យដឹកនាំបានសង្ឃឹមយ៉ាងមុតមាំថាសៀវភៅមួយក្បាលនេះគឺជាឯកសារជំនួយស្មារតីដល់បងប្អូនទាំងអស់គ្នានៅក្នុងរឿព្រហ្មទណ្ឌផងដែរ។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........ ១

## ជំពូកទី១

## ចៅក្រមអសនៈ

**១.១ ចៅក្រម** ........ ៤

១.១.១ សញ្ញាណទូទៅរបស់ចៅក្រម ........ ៤

១.១.២ ឋានន្តរស័ក្តិ និងថ្នាក់ ........ ៥

**១.២ ចៅក្រមស៊ើបសួរ** ........ ៩

១.២.១ ការចាត់តាំងតាមផ្លូវតុលាការ ........ ១០

១.២.២ ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ ........ ១១

## ជំពូកទី២

## ការស៊ើបសួរ

**២.១ កិច្ចរបស់ចៅក្រមស៊ើបសួរ** ........ ១២

២.១.១ ការសម្ងាត់នៃការស៊ើបសួរ ........ ១២

២.១.២ សមត្ថកិច្ចដែនដី ........ ១៣

២.១.៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ ១៣

២.១.៤ វិសាលភាពនៃការប្ដឹង ........ ១៤

២.១.៥ ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា ........ ១៤

**២.២ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ........ ១៥

២.២.១ ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ........ ១៥

២.២.២ ការសួរចម្លើយជនត្រូវចោទ ........ ១៦

២.២.៣ ការឆែកឆេរ និងការចាប់យកវត្ថុតាង ........ ១៨

២.២.៤ កោសលវិច័យ ........ ១៩

២.២.៥ ការស្តាប់ទូរស័ព្ទ ........ ១៩

២.២.៦ ដីកាចាត់ឱ្យស៊ើបសួរជំនួស ........ ២០

## ជំពូកទី៣

## វិធានការនិរន្តរាយ

**៣.១ ដីកា** ........ ២២

៣.១.១ ដីកាបង្គាប់ឱ្យចូលខ្លួន ........ ២២

៣.១.២ ដីកាបង្គាប់ឱ្យនាំខ្លួន ........ ២៣

៣.១.៣ ដីកាបង្គាប់ឱ្យចាប់ខ្លួន ........ ២៤

៣.១.៤ ការឃុំខ្លួនបណ្តោះអាសន្ន ........ ២៦

៣.១.៥ ការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ២៩

## ជំពូកទី៤

## ការបិទការស៊ើបសួរ

**៤.១ ដីកាដំណោះស្រាយ** ........ ៣៣

៤.១.១ ដីកាដំណោះស្រាយទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ននិងការត្រួត ពិនិត្យតាម ផ្លូវតុលាការ ........ ៣៤

**៤.២ ការបិទការស៊ើបសួរតាមបណ្តឹងសុំរបស់ភាគី** ........ ៣៤

**៤.៣ មោឃភាពនៃកិច្ចនីតិវិធី** ........ ៣៥

៤.៣.១ អានុភាពនៃមោឃកម្ម ........ ៣៥

**៤.៤ បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ** ........ ៣៦

**សេចក្តីសន្និដ្ឋាន**........................................................................................... ៣៩
**អនុសាសន៍**................................................................................................ ៤០
**ឯកសារយោង និង ឯកសារពិគ្រោះ**.....................................................................

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅតាមសង្គមនីមួយៗគឺតែងតែមានច្បាប់សម្រាប់ឱ្យប្រជាជនរបស់ខ្លួន អនុវត្តដើម្បីធានាឱ្យបាននូវ ការទទួលបានសិទ្ធរបស់ពលរដ្ឋគ្រប់ៗរូប ដែលច្បាប់ទាំងនោះបានបែងចែកជាច្រើនបែប ច្រើនសណ្ឋានទៅតាមប្រទេសនីមួយៗផងដែរ។ បើយើងងាកទៅមើលប្រព័ន្ធច្បាប់ធំៗនៅលើសកលលោកយើង វិញគឺគេបានបែងចែកជាបីប្រព័ន្ធធំៗ ដែលមានដូចជា ប្រព័ន្ធច្បាប់ COMMEND LAW, CIVIL LAW និង ប្រព័ន្ធច្បាប់សង្គមនិយម។ ចំពោះប្រទេសកម្ពុជាយើងវិញបានសម្រេចចិត្តជ្រើសរើសនូវ ប្រព័ន្ធច្បាប់ CIVIL LAW សម្រាប់យកមកអនុវត្ត ដែលប្រព័ន្ធច្បាប់ (CIVIL LAW) នេះទៀតសោត គឺវាពិតជាមានភាពងាយស្រួលដល់គូភាគី ពីព្រោះថាប្រព័ន្ធនេះគឺបានបង្កើតឱ្យមាននូវយុត្តាធិការស៊ើបសួរ ដែលជាតួនាទីរបស់ចៅក្រមស៊ើបសួរនៅក្នុងប្រព័ន្ធតុលាការទូទាំងប្រទេសនៃព្រះរាជាណាចក្រកម្ពុជាយើង ដែលខុសពីប្រព័ន្ធច្បាប់ COMMEND LAW ដែលពុំមាន យុត្តាធិការស៊ើបសួរនោះឡើយ ពោលគឺប្រសិនបើចង់ស្វែងរកភស្តុតាងដោះបន្ទុកគឺពួកគេ ទាល់តែធ្វើការជួលទៅលើអ្នកស៊ើបអង្កេត ឬក៏ជួលទៅលើមេធាវីដែលមានជំនាញខ្លាំងពូកែសម្រាប់ស្វែងរកភស្តុតាងដែលសោហ៊ុយនេះគឺអ្នកជួលផ្ទាល់ជាអ្នកចេញ។

មុននឹងឈានទៅដល់ការបកស្រាយដំណាក់កាលនៃការស៊ើបសួរនេះដែរ គឺពួកយើងសុំរំលឹកទៅដល់ដំណាក់កាលទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌជាមុនសិន។ ចំពោះរឿងក្តីព្រហ្មទណ្ឌបានបែងចែកជា ៤ដំណាក់កាលដែលក្នុងនោះមានដូចជា៖

- ដំណាក់កាលទី១៖ ជាដំណាក់កាលនគរបាលយុត្តិធម៌ ដែលស៊ើបអង្កេតទៅលើបទល្មើសជាក់ស្តែង និងបើកការស៊ើបអង្កេតបឋមក្រោមការគ្រប់គ្រងរបស់ព្រះរាជអាជ្ញា។
- ដំណាក់កាលទី២៖ ជាដំណាក់កាលនៃការចោទប្រកាន់ដែលធ្វើដោយព្រះរាជអាជ្ញា។
- ដំណាក់កាលទី៣៖ ជាដំណាក់កាលនៃការស៊ើបសួរដែលជាតួនាទីរបស់ចៅក្រមស៊ើបសួរ។
- ដំណាក់កាលទី៤៖ ជាដំណាក់កាលនៃការជំនុំជម្រះ ពោលគឺចូលសវនាការ។

តើហេតុអ្វីទើបបានជាគេបង្កើតឱ្យមានយុត្តាធិការស៊ើបសួរនេះ?

យុត្តាធិកាស៊ើបសួរ គឺជានីតិវិធីមួយដ៏សំខាន់នៅក្នុងនីតិវិធីព្រហ្មទណ្ឌ ព្រោះដំណាក់កាលនេះត្រូវបានធ្វើឡើងដោយគោរពសិទ្ធិរបស់ភាគី ទោះជាជនរងគ្រោះ ឬជនត្រូវចោទក៏ដោយ ពោលគឺចៅក្រមស៊ើបសួរ ជាអ្នកស្វែងរកប្រមូលភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដើម្បីធ្វើយ៉ាងណាធានាឱ្យបាននូវសមភាពរវាងគូ

ភាគី និងស្វែងរកឱ្យឃើញនូវការពិត ដោយអនុលោមតាមច្បាប់។ មូលហេតុដែលគេចាំបាច់ឱ្យមានយុត្តាធិការស៊ើបសួរនេះឡើងមក គឺគេមានគោលបំណងធំៗជាច្រើន ដែលក្នុងនោះមានដូចជាៈ

**ការស្វែងរកភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកៈ** យុត្តាធិការស៊ើបសួរគឺចំណុះឱ្យស្ថាប័នតុលាការដែលនៅក្នុងដំណាក់កាលនេះគឺចៅក្រមស៊ើបសួរមានតួនាទីស្វែងរកភស្តុតាងទាំងដោះបន្ទុក និងទាំងភស្តុតាងដាក់បន្ទុកជូនភាគីក្តីទាំងសងខាងដើម្បីស្វែងរកឱ្យឃើញការពិតដោយ អនុលោមតាមច្បាប់ ដែលខុសពីដំណាក់កាលអយ្យការគឺស្វែងរកតែភស្តុតាង ដាក់បន្ទុកតែប៉ុណ្ណោះទៅលើជនត្រូវចោទ(**ជនបង្ក**) ដែលអនុវត្តដោយព្រះរាជអាជ្ញា។

**ធានាឱ្យមានសមភាពចំពោះមុខច្បាប់ៈ** ដូចដែលយើងបានបញ្ជាក់ពីខាងលើហើយអញ្ចឹងថាប្រទេសកម្ពុជាយើងបានប្រកាន់ភ្ជាប់នូវប្រព័ន្ធច្បាប់ CIVIL LAW ដូច្នេះហើយបុគ្គលគ្រប់រូបដែលនៅក្នុងរឿងក្តី ព្រហ្មទណ្ឌមានសិទ្ធិទទួលបានស្មើៗគ្នា ទាំងការស្វែងរកភស្តុតាង និងការស្វែងរកយុត្តិធម៌ជូនជនបរិសុទ្ធ ដោយចៅក្រមស៊ើបសួរ និងគ្មានភាពលំអៀង ហើយមិនមានការចំណាយសោហ៊ុយច្រើន ដែលវាខុសពីប្រព័ន្ធច្បាប់ COMMEND LAW គឺវាហាក់ដូចជា មានការលំបាកចំពោះជនដែលមិនសូវជាមានលទ្ធភាព ចំពោះការយកប្រាក់ទៅរកសេវាមេធាវីល្អៗ មកស៊ើបអង្កេត ជូនខ្លួននោះឡើយ។

**ចំណាយពេលវេលាតែចំនេញយុត្តិធម៌ៈ** បើទោះបីជាមានការបង្កើតឱ្យមានយុត្តាធិការស៊ើបសួរនេះ មានការចាយពេលវេលាបន្ថែមទៅលើនីតិវិធីក៏ដោយ តែវាក៏បានធានាឱ្យបាននូវភាពច្បាស់លាស់ ក្នុងការប្រមូលភស្តុតាងឱ្យបានគ្រប់ជ្រុងជ្រោយកុំឱ្យមាននូវចន្លោះប្រហោងមុននឹងធ្វើការជំនុំជម្រះ ពោលគឺសុខចិត្តចំណាយពេល ក៏ប្រសើរជាងធ្វើការជំនុំជម្រះដោយមិនមានភស្តុតាងគ្រប់គ្រាន់។

ការស៊ើបសួរ គឺជាសិទ្ធិ និងតួនាទីក្នុងការបំពេញកិច្ចរបស់ចៅក្រមស៊ើបសួរ ក្នុងការស្រាវជ្រាវចំពោះអង្គហេតុនៃបទល្មើសព្រហ្មទណ្ឌក្រោយពីទទួលបាន ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ។ ចំពោះកិច្ចស៊ើបសួរទាំងអស់ ត្រូវបានអនុវត្ត និងដឹកនាំផ្ទាល់ដោយចៅក្រមស៊ើបសួរ ដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធ និងបញ្ជាក់ពីការពិតនៃអង្គហេតុព្រហ្មទណ្ឌចាប់តាំងពីការចាប់ផ្តើមស្រាវជ្រាវរហូតដល់បញ្ចប់ការស៊ើបសួរ។ ការស៊ើបសួរត្រូវធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ រីឯចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬ មិនធ្វើក៏បាន។ ចំពោះចៅក្រមស៊ើបសួរដែលបានបំពេញកិច្ចជាចៅក្រមរួចហើយគឺមិនមានការអនុញ្ញាត ឱ្យចៅក្រមដដែលនេះដើរតួជាចៅក្រមជំនុំជំម្រះឡើយព្រោះវាអាចនាំឱ្យមានការលំអៀងនៅក្នុងនីតិវិធី។ ការបំពាន និងការប្រព្រឹត្តិផ្ទុយពីនីតិវិធី វានិងក្លាយទៅជាកម្មវត្ថុនៃការប្តឹងសុំមោឃភាពនៃកិច្ចនីតិវិធី។

កិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរមានជាច្រើនកិច្ចដែលត្រូវបំពេញនៅក្នុងដំណាក់កាលនេះ ដែលក្នុងនោះមានដូចជាៈ ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ, ការសួរចម្លើយជនត្រូវចោទ, ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះការស្ដាប់ចម្លើយសាក្សី, ការឆែកឆេរ, ការចាប់យកវត្ថុតាង, កោសលវិច័យ, ការស្ដាប់ទូរស័ព្ទ, ការចាត់ឱ្យស៊ើបសួរជំនួស, វិធានការនិរន្តរាយ ។ បន្ថិចទៀតនេះយើងនឹងនាំអារម្មណ៍អ្នកទាំងអស់គ្នាឱ្យកាន់តែស្គាល់ឲ្យបានច្បាស់ អំពីដំណាក់កាលនៃការ ស៊ើបសួររបស់ចៅក្រមស៊ើបសួរថា ៖

តើត្រូវបំពេញលក្ខខណ្ឌបែបណាទើបអាចក្លាយជាចៅក្រម?

តើចៅក្រមស៊ើបសួរមានតួនាទីអ្វីខ្លះ?

តើចៅក្រមនិងទទួលទណ្ឌកម្មបែបណាពេលខ្លួនបានប្រព្រឹត្តកំហុស?

តើទំនាក់ទំនងរវាងចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាមានអ្វីខ្លះ?

ដើម្បីធ្វើការបកស្រាយទៅលើប្រធានបទ ចៅក្រមស៊ើបសួរ នេះឲ្យកាន់តែស៊ីជម្រៅ យើងសុំធ្វើការបែងចែកជា ៥ ជំពូក ដែលរួមមានៈ

**ជំពូក១ ចៅក្រមអសនៈ**

**ជំពូក២ ការស៊ើបសួរ**

**ជំពូក៣ វិធានការនិរន្តរាយ**

**ជំពូក៤ ការបិទការស៊ើបសួរ**

**ជំពូក៥ ការប្ដឹងចំពោះដីការបស់ចៅក្រមស៊ើបសួរ និងមោឃភាព។**

# ជំពូកទី១

# ចៅក្រមអសនៈ

# ជំពូកទី១
# ចៅក្រមអសនៈ

## ១.១ ចៅក្រម

### ១.១.១ សញ្ញាណទូទៅរបស់ចៅក្រម

ចៅក្រម និង ព្រះរាជអាជ្ញាទាំងឡាយមានគោលបំណងធានាឯករាជ្យនៃអំណាចតុលាការដោយស្របទៅតាមរដ្ឋធម្មនុញ្ញ[1]នៃព្រះរាជាណាចក្រកម្ពុជា មិនតែប៉ុណ្ណោះចៅក្រមនិងព្រះរាជអាជ្ញាទាំងឡាយ ដែលបំពេញមុខងាររបស់ខ្លួនទាំងស្ថាប័នតុលាការក្តី ស្ថាប័នអយ្យការក្តី គឺត្រូវតែមានកាតព្វកិច្ច និង សម្របខ្លួនទៅតាមច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញានៅពេលបំពេញមុខងាររបស់ខ្លួន ជូនប្រជាពលរដ្ឋដើម្បីធានាថាបានបម្រើការជូនប្រជាពលរដ្ឋដោយចិត្តស្មោះសរនិងបរិសុទ្ធ។ ប៉ុន្តែចៅក្រម និងព្រះរាជអាជ្ញាត្រូវបានលើកលែងដោយមិនចាំបាច់គោរពតាមគោលការណ៍នៃច្បាប់ ស្តីពីលក្ខន្តិកៈចៅក្រមនិង ព្រះរាជអាជ្ញានេះក៏បានដែរប្រសិនបើច្បាប់ណាមួយបានកំណត់ ផ្សេងពីនេះ។ **ឧទាហរណ៍**៖ ច្បាប់ស្តីពីការរៀបចំអង្គតុលាការ បានចែងពីផ្នែកនេះដែរ។

មុននឹងឈានទៅដល់ការបកស្រាយអំពីសញ្ញាណនៃចៅក្រម ឱ្យកាន់តែបានស៊ីជម្រៅនោះ យើងនាំគ្នាមកស្គាល់វាក្យសព្ទបច្ចេកទេសជាមុនសិន៖

- ចៅក្រម ៖ សំដៅដល់ចៅក្រមអសនៈ ដែលចៅក្រមអសនៈនេះរួមមានចៅក្រមជំនុំជម្រះ និងចៅក្រមស៊ើបសួរ។
- ព្រះរាជអាជ្ញា ៖ សំដៅដល់ព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងអគ្គព្រះរាជអាជ្ញា។
- អង្គចៅក្រម ៖ សំដៅទៅដល់ទាំងចៅក្រមនិងព្រះរាជអាជ្ញា។

នៅក្នុងអាជីពរបស់ខ្លួន ចៅក្រម អាចត្រូវបានតែងតាំងជាព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាអាចត្រូវបានតែងតាំងជាចៅក្រមបានដែរ ពីព្រោះថាចៅក្រមនិងព្រះរាជអាជ្ញាគឺត្រូវឆ្លងកាត់ ការប្រលងជាមួយគ្នា រៀនជាមួយគ្នា ហើយមុននឹងបានចូលបំពេញការងារ គឺត្រូវឆ្លងកាត់ការប្រលង សាជាថ្មីម្តងទៀតមុន ប្រកបវិជ្ជាជីវៈជា ចៅក្រម ឬព្រះរាជអាជ្ញា។ ដូច្នេះហើយ ពេលពួកគាត់ចេញធ្វើការមិនប្រាកដថាពួកគាត់បានធ្វើ ចៅក្រម ឬព្រះរាជអាជ្ញាឡើយ ពោលគឺគោរពតាមការតែងតាំងជាមុនសិន (**ព្រះរាជក្រឹត្យ**)។

មួយវិញទៀតចៅក្រម ទាំងឡាយត្រូវសម្រេចសេចក្តីលើសុំណុំរឿងទាំងឡាយរបស់ខ្លួនដោយមិន លំអៀងដោយឈរ លើគោលការណ៍គោរពច្បាប់ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬបំភិតបំភ័យ ណាមួយពីមជ្ឈដ្ឋានជុំវិញខ្លួនឡើយ។ ជាទូទៅ ចៅក្រម និងព្រះរាជអាជ្ញា មិនទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌ ទណ្ឌកម្មផ្នែករដ្ឋ

[1] មាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

ប្បវេណី ឬទណ្ឌកម្មផ្នែកវិន័យ ចំពោះសេក្តីសម្រេចរបស់ខ្លួននៅពេលបំពេញតួនាទីឡើយ ពោលគឺ វាជាឆន្ទានុសិទ្ធិដែលគេបានផ្តល់ជូនពួកគាត់ក្នុងការសម្រេចទៅលើដំណាក់កាលណាមួយនៅក្នុងរឿងក្តីនានា **ឧទាហរណ៏៖** នៅក្នុងដំណាក់កាលព្រះរាជអាជ្ញាមានសិទ្ធិចោទប្រកាន់ទៅលើជនសង្ស័យយ៉ាងណាក៏បានដែរ ព្រោះជាអំណាចដែលច្បាប់ប្រគល់ឱ្យ។ អញ្ចឹងហើយទោះជាអង្គចៅក្រមសម្រេចយ៉ាងណាក៏ដោយគូរភាគីនៃ រឿងក្តីត្រូវតែទទួលយកនៃការសម្រេចទាំងនេះ តែប្រសិនបើគូរភាគីនៃ រឿងក្តីមិនសុខចិត្តនោះ ពួកគេអាចប្តឹងជំទាស់បាន ចំពោះសេចក្តីសម្រេចទាំងនេះ ទៅតុលាការជាន់ ខ្ពស់ផងដែរ។

**១.១.២ ឋានន្តរស័ក្តិ និងថ្នាក់**

ឋានន្តរស័ក្តិ របស់ចៅក្រមបានចែកជាបីថ្នាក់[2]៖ ឧត្តមចៅក្រម វរៈចៅក្រម និង អនុចៅក្រម ដែលត្រូវបានកំណត់ដោយព្រះរាជក្រឹត្យ។ ចំណែកឯការទទួលបានប្រាក់បៀវត្សរ៍វិញនោះយើងឃើញថា ចៅក្រមគឺបានទទួលបានទៅតាមឋានន្តរស័ក្តិ និងតាមថ្នាក់របស់ខ្លួន។

ចំពោះការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវធ្វើតាមវេនជ្រើសរើស ឬតាមវេនអតីតភាព ស្របតាមតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗ ហើយក៏ត្រូវបានធ្វើឡើងដោយកំណត់តាមព្រះរាជក្រឹត្យ។

ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ[3]របស់ចៅក្រមត្រូវគោរពតាម៖

- ការគោរពវិន័យការងារបានត្រឹមត្រូវ
- ការសម្រេចភារកិច្ចបានល្អ
- កិរិយាមាយាទ និងសីលធម៌ល្អ មិនធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម
- ការឆ្លងកាត់វគ្គបណ្តុះបណ្តាលនានា ឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា។

ហើយការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមានសមាសភាពនៃគណៈកម្មការរួមមាន៖

- រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ០១ រូប ជាប្រធាន
- អនុប្រធានតុលាការកំពូល ០១ រូប អនុប្រធាន
- អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ០១ រូប អនុប្រធាន
- ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ សមាជិក
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៏ភ្នំពេញ សមាជិក
- ប្រធានសាលាដំបូងរាជធានីភ្នំពេញ សមាជិក

[2] មាត្រា១០ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[3] មាត្រា២៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

- ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ សមាជិក
- អគ្គលេខាធិការនៃឧត្តមក្រមប្រឹក្សានៃអង្គចៅក្រម លេខាធិការ។

ម៉្យាងទៀតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចតែងតាំងសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ដើម្បីជាជំនួយការឱ្យគណៈកម្មការនេះ។

ចៅក្រមក្នុងឋានន្តរស័ក្តិតែមួយ អាចឡើងថ្នាក់បានម្តងមួយថ្នាក់។ ក្នុងករណីចាំបាច់ចៅក្រមអាចប្តូរឋានន្តរស័ក្តិបានតាមរយៈការប្រឡង។

### **១.១.២.១ ការជ្រើសរើសចៅក្រម**

ត្រូវបានអនុញ្ញាតឱ្យប្រឡងជ្រើសរើសជាសិស្សចៅក្រម [4] ចំពោះបេក្ខជនដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវមានសញ្ជាតិខ្មែរពីកំណើត
- មានអាយុ ៣៥ ឆ្នាំ យ៉ាងច្រើនចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៤០ ឆ្នាំ យ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការ គិតមកដល់ថ្ងៃប្រឡង
- ត្រូវមានបរិញ្ញាបត្រច្បាប់ឡើងទៅ
- មិនដែលមានទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋ
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។

ការកំណត់ចំនួននៃការជ្រើសរើសសិស្សចៅក្រម ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ប៉ុន្តែមានលក្ខណៈពិសេសចំពោះការជ្រើសរើសបញ្ចូលក្នុងក្រមខណ្ឌចៅក្រម អាចធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងពីក្នុងចំណោមមន្ត្រីរាជការ ក្រឡាបញ្ជី និងមេធាវី ដែលមានសញ្ញាបត្រ ចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងមានបទពិសោធន៍ក្នុងវិស័យច្បាប់ ឬ បានបំពេញវិជ្ជាជីវៈ (**សម្រាប់មេធាវី**) យ៉ាងតិច ៥ឆ្នាំ អាចចុះឈ្មោះចូលរួមប្រឡងប្រជែងជាសិស្សចៅក្រមបាន ប្រសិនបើ មន្ត្រីរាជការ ក្រឡាបញ្ជី និង មេធាវី មានអាយុមិនលើសពី ៤៥ ឆ្នាំ ដែលគិតមកដល់ថ្ងៃប្រឡង។

[4] មាត្រា១៩ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

#### ១.១.២.២ ការតែងតាំង និង ការផ្លាស់ប្តូរ

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេច នឹងលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្អាក់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះចៅក្រមទាំងអស់[5]។

**ចៅក្រមអាចត្រូវបានអនុញ្ញាតឱ្យផ្អាក់ពីមុខងារ ឬឱ្យដាក់ក្រៅក្របខណ្ឌចៅក្រមបាន៖** តាមការស្នើសុំរបស់សាមីខ្លួន ឬស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន។ ក្នុងករណីចាំបាច់ដែលត្រូវបំពេញការងារជាបណ្តោះអាសន្ន នៅក្នុងតំណែងមុខងារសាធារណៈ តំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬតំណែងទីប្រឹក្សាគ្រប់ឋានានុក្រម ចៅក្រមអាចសុំផ្អាក់ពីមុខងារបាន។ ការអនុញ្ញាតឱ្យផ្អាក់ពីមុខងារនេះ ត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន ឬស្ថាប័នផ្សេងដោយមានការយល់ព្រមរបស់សាមីខ្លួន។ ក្នុងរយៈពេលនៃការអនុញ្ញាតឱ្យផ្អាក់ពីមុខងារ ចៅក្រមនោះ ត្រូវបន្តទទួលប្រាក់បៀវត្ស ព្រមទាំងសិទ្ធិក្នុងការឡើងថ្នាក់ ឬឋានន្តរស័ក្តិ និងសិទ្ធិក្នុងការចូលនិវត្តន៍របស់ខ្លួន ប៉ុន្តែពុំមានប្រាក់បំណាច់មុខងារ និងប្រាក់រង្វាន់ផ្សេងៗទៀតនៃមុខងារដើមរបស់ខ្លួនទេ។ ចៅក្រមអាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌចៅក្រម ប្រសិនបើចៅក្រមរូបនោះមិនអើរពើក្នុងការដាក់ពាក្យស្នើសុំផ្អាក់ពីមុខងារ ក្នុងរយៈពេល ៣០ថ្ងៃ។ តែប្រសិនចៅក្រមរូបនេះបានដាក់ពាក្យស្នើសុំផ្អាក់ពីមុខងារ ជាលាយលក្ខណ៍អក្សរ ចៅក្រមរូបនោះត្រូវតែមានការស្ម័គ្រចិត្តពីសាមីខ្លួនផ្ទាល់ ក៏ដូចជាមានការអនុញ្ញាតពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**ការស្នើសុំនៅទំនេរ៖** ក្នុងករណីចាំបាច់ ដោយមូលហេតុផ្ទាល់ខ្លួន គ្រួសារ វិសមិតភាព ចៅក្រមអាចស្នើសុំនៅទំនេរគ្មានប្រាក់បៀវត្សសម្រាប់រយៈពេលកំណត់ណាមួយ តាមពាក្យសុំរបស់សាមីខ្លួន។ ការអនុញ្ញាតឱ្យនៅទំនេរគ្មានបៀវត្សអាចធ្វើឡើងសម្រាប់រយៈពេលម្តង ១ ឆ្នាំ ឬ ម្តង ២ ឆ្នាំ។ ការអនុញ្ញាតឱ្យនៅទំនេរនេះអាចធ្វើបានតែពីរដងគត់ ហើយរយៈពេលសរុបនៃការអនុញ្ញាតនេះមិនត្រូវលើស ៤ ឆ្នាំ ឡើយ ពាក្យសុំនេះត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីពិនិត្យ និងសម្រេច។ ចំពោះការលុបឈ្មោះចេញពីក្រមខណ្ឌចៅក្រម ក្នុងករណី ចៅក្រមណាដែលពុំបានដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬពុំបានចូលបំពេញមុខងាររបស់ខ្លួនវិញយ៉ាងយូរ ៣០ ថ្ងៃ ចាប់ពីផុតរយៈពេលនៃភាពទំនេរនោះទេ ។

#### ១.១.២.៣ ភាតព្វកិច្ចចៅក្រម

ចៅក្រមត្រូវមានកាតព្វកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យ នឹងគោរពឱ្យបាន ម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន។ ក្នុងជីវភាពរបស់ខ្លួន ចៅក្រមមិនត្រូវប្រព្រឹត្តអំពើណាមួយ នាំអាប់អោនកិត្តិយស សេចក្តី

[5] មាត្រា៤៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

ថ្លៃថ្នូររបស់ខ្លួន និងកិត្យានុភាពនៃអង្គចៅក្រមឡើយ។ ចំណែកឯក្នុងវិស័យ នយោបាយវិញ ចៅក្រមត្រូវប្រកាន់ភ្ជាប់នូវឥរិយាបថអព្យាក្រឹត ពោលគឺនៅកណ្តាល មិនលំអៀងទៅខាងណា មួយឡើយ[6]។

ចៅក្រមទាំងអស់ មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬអវត្តមានដោយគ្មាន ការអនុញ្ញាតពីថ្នាក់លើផ្ទាល់របស់ខ្លួនជាមុនឡើយ បើការបោះបង់ការងារ ឬអវត្តមានឥតច្បាប់ ដោយពុំមានមូលហេតុ លើសពី៣០ ថ្ងៃ ហើយចៅក្រមនៅតែមិនត្រលប់មកបំពេញ មុខងារវិញក្នុងការដាក់កំហិតចំនួន២ដងនោះ ត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌ។

ចៅក្រមគ្រប់រូបត្រូវសុំការអនុញ្ញាតជា មុនទៅឧត្តមក្រុមប្រឹក្សានៃ អង្គចៅក្រម មុននិង ធ្វើការផ្សាយតាមគ្រប់មធ្យោបាយ នៃសំណុំរឿងទាំងមូល ឬមួយផ្នែក។ ប្រសិនបើហ៊ានធ្វើទាំងបំពាន ចៅក្រមរូបនោះ នឹងទទួលរងទោសវិន័យ ដែលមានចំនួន២ ថ្នាក់ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌប្រសិនបើមាន។ ដែលទោសវិន័យទាំង២ [7]នេះមានដូចជា ៖

**ថ្នាក់ទី១៖**

ក. ការស្តីបន្ទោសដោយផ្ទាល់មាត់

ខ. ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ. ការផ្អាកមិនឱ្យចុះឈ្មោះក្នុងតារាងតំឡើងថ្នាក់ ឬលុបឈ្មោះចេញពីតារាងតំឡើងថ្នាក់

**ថ្នាក់ទី២៖**

ក. ការផ្លាស់ដោយបង្ខំ អាចតម្រូវឱ្យទទួលការបណ្តុះបណ្តាលបន្ថែម

ខ. ការព្យួរពីការងារមិនឱ្យមានបៀវត្ស ក្នុងរយៈពេលមិនលើសពី១ឆ្នាំ

គ. ការបន្ថយមួយថ្នាក់ ឬច្រើនជាងនេះ

ឃ. ការដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ

ច. ការបណ្តេញចេញពីក្របខណ្ឌ

ទណ្ឌកម្មថ្នាក់ទី២ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គ ចៅក្រម។

[6] មាត្រា៥០ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[7] មាត្រា៥៥ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

### ១.១.២.៤ ការចោទប្រកាន់តាមផ្លូវតុលាការ

ចៅក្រមដែលបានប្រព្រឹត្តបទល្មើសណាមួយ អាចត្រូវបានចោទប្រកាន់បានតាមផ្លូវតុលាការ ដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចផ្ទេរសមត្ថកិច្ចទៅសាលាដំបូងផ្សេងក្រៅពីសាលាដំបូងដែលចៅក្រមនោះបំពេញមុខងារ[8]។

ក្នុងករណីដែលចៅក្រមណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌហើយត្រូវបានព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ នោះព្រះរាជអាជ្ញាត្រូវជូនដំណឹងពីការចោទប្រកាន់នេះ ទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងអំឡុងពេល ៧២ ម៉ោង ហើយបើឈានទៅដល់ការចាប់ខ្លួន ឬឃាត់ខ្លួនចៅក្រមនោះ អ្នកដែលចាប់ ឬឃាត់ខ្លួនត្រូវជូនដំណឹងទៅរដ្ឋ

មន្ត្រីក្រសួងយុត្តិធម៌អំពីចំណាត់ការនេះ។ បន្ទាប់មករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវបញ្ជូនដំណឹងនេះជាបន្ទាន់ទៅកាន់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ចៅក្រមដែលមានការចោទប្រកាន់ពីបទល្មើសមជ្ឈិម ឬឧក្រិដ្ឋ ត្រូវបានផ្អាកសកម្មភាពមុខងារជាចៅក្រមដោយស្វ័យប្រវត្តិ ព្រមទាំងប្រាក់បៀវត្សផងដែរ[9]។ ប្រសិនបើចៅក្រមរូបនេះទទួលបានការលើកលែងចោទប្រកាន់ ចៅក្រមរូបនោះត្រូវបានអនុញ្ញាតឱ្យចូលបម្រើការវិញភ្លាមនឹងទទួលបានមកវិញនូវអតីតប្រាក់បៀវត្ស ឋាននន្តរស័ក្តិ ពីមុនមកវិញទាំងអស់។

បើទោះបីជាមានការសម្រេចលើកលែងចោទប្រកាន់ក៏ដោយចៅក្រមរូបនោះគឺរងទណ្ឌកម្មវិន័យដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបន្ថែមពីព្រោះថា ចៅក្រមរូបនោះបានប្រព្រឹត្តខុសពីសីលធម៌ និងវិជ្ជាជីវៈជាចៅក្រម។ ប្រសិនបើចៅក្រមរូបនោះពិតជាបានប្រព្រឹត្តបទល្មើស នឹងទទួលរងទោសហើយគ្មានការព្យួរទោសទេចៅក្រមរូបនោះត្រូវលុបចេញពីក្របខណ្ឌ គិតពីថ្ងៃសាលក្រម ឬសាលដីកា ចូលជាស្ថាពរ។

## ១.២ ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរមានតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកភស្តុតាងទាំងដោះបន្ទុកនិងដាក់បន្ទុកជូនគូភាគីក្នុងរឿងក្តីនិយាយជារួមគឺចៅក្រមរូបនេះធ្វើការជួយ ក៏ដូចជាស្វែងរកការពិតជូនគូរភាគីដោយអនុលោមតាមច្បាប់។

ចៅក្រមស៊ើបសួរមានតួនាទីស្រាវជ្រាវសុំណុំរឿង ដែលបានប្តឹងមកខ្លួនតាមរយៈព្រះរាជអាជ្ញាដោយដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ពោលគឺ វាជាដំណាក់កាលទី៣ នៃដំណើរការនីតិវិធីក្នុងរឿងព្រហ្មទណ្ឌ ដែលយើងសុទ្ធ តែដឹងថា ដំណើរនៅក្នុងនីតិវិធីព្រហ្មទណ្ឌបានបែងចែកជា **៤ដំណាក់កាលគឺ៖**

**ដំណាក់កាលទី១** គឺដំណាក់កាលនគរបាលយុត្តិធម៌ ក្រោមការទទួលខុសត្រូវនឹងគ្រប់គ្រងរបស់ព្រះរាជអាជ្ញា។

[8] មាត្រា៥៧ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[9] មាត្រា៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

**ដំណាក់កាលទី២** គឺដំណាក់កាលនៃការចោទប្រកាន់ (ដំណាក់កាលព្រះរាជអាជ្ញា)។

**ដំណាក់កាលទី៣** គឺដំណាក់កាលនៃការស៊ើបសួរ (ដំណាក់កាលចៅក្រមស៊ើបសួរ)។

**ដំណាក់កាលទី៤** គឺដំណាក់កាលជំនុំជម្រះ។

ដំណាក់កាលនៃចៅក្រមស៊ើបសួរនេះគឺកកើតឡើងមកបានលុះត្រាមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពីសំណាក់ព្រះរាជអាជ្ញា ពោលគឺជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាបានបែងចែកជា៣ គឺៈ

- ការបើកការស៊ើបសួរ (ឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរ)
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ (មិនឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរ)
- តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម (មិនឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរ)

ជាទូទៅការស៊ើបសួរត្រូវតែ ធ្វើជាដាច់ខាតនៅពេលមាន បទឧក្រិដ្ឋបានកើតឡើង[10]។ ចំណែកឯក្នុងបទមជ្ឈិមវិញ ការស៊ើបសួរអាចធ្វើក៏បាន មិនធ្វើក៏បាន នេះគឺវាស្ថិតទៅលើជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាថា តើគាត់ជ្រើសរើសក្នុង ការចោទប្រកាន់មួយណា។

### ១.២.១ ការចាត់តាំងតាមផ្លូវតុលាការ

ចៅក្រមនៃសាលាដំបូងម្នាក់ៗ ត្រូវបានចាត់តាំងដោយសេចក្ដីសម្រេចពិសេសរបស់ប្រធានសាលាដំបូងជារៀងរាល់ឆ្នាំ ដើម្បីឱ្យបំពេញភារកិច្ចជាចៅក្រមស៊ើបសួរ។

ប្រសិនបើចៅក្រមស៊ើបសួរណាម្នាក់ ដែលពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាក់ ដោយមានជំងឺ ឬ ដោយមានមូលហេតុផ្សេងដទៃទៀត ចៅក្រមផ្សេងទៀតនៃតុលាការដដែលត្រូវបានចាត់តាំងជាបណ្ដោះអាសន្នដោយប្រធានតុលាការ ដើម្បីបំពេញមុខងារស៊ើបសួរ។ ហើយក្នុងករណីដែលពុំមានចៅក្រមស៊ើបសួរទេ ចៅក្រមផ្សេងទៀតនៃតុលាការដដែល អាចត្រូវបានចាត់តាំងជាបណ្ដោះអាសន្នដោយប្រធានតុលាការដើម្បីបំពេញមុខងារស៊ើបសួរ។ សេចក្ដីសម្រេចរបស់ប្រធានតុលាការក្នុងការចាត់តាំងនេះពុំបើកផ្លូវតវ៉ាឡើយ គឺមានន័យថា សេចក្ដីសម្រេចរបស់ប្រធានតុលាការ នៅក្នុងករណីនេះ យើងសង្កេតឃើញថាការសម្រេចនេះមានលក្ខណៈដាច់ខាត ព្រោះជាសេចក្ដីសម្រេចមួយប្រភេទដែលបិទផ្លូវតវ៉ា[11]។

[10] មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[11] មាត្រា៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ១.២.២ ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ

ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរមួយឱ្យចៅក្រមស៊ើបសួរមួយរូបទៀតគឺអាចធ្វើឡើងបាន ដោយសារជាផលប្រយោជន៍រដ្ឋបាលដ៏ល្អនៃវិស័យយុត្តិធម៌ ពោលគឺកុំឱ្យមានការកកស្ទះនៃសំណុំរឿង ឬក៏មាន មូលហេតុនៃការប្តឹងជំទាស់ចៅក្រមអសនៈ [12]។

ជាក់ស្តែងនាពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថាមានចំណាត់ការណ៍ពីសំណាក់ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ថ្មី បានចេញយុទ្ធនាការដោះស្រាយបញ្ហាកកស្ទះ សំណុំរឿង ដោយប្រើយុត្តិសាស្ត្រ ចល័តចៅក្រម នៃសាលាជម្រះក្តីនានា ដែលមិនសូវមានសំណុំរឿងកកស្ទះ មកជួយដោះស្រាយសាលាជម្រះក្តី ដែលមានការកក ស្ទះសំណុំឱ្យបានកាន់តែលឿនជាងមុន ដើម្បីរកយុត្តិធម៌ជូនអ្នកត្រឹមត្រូវ ឱ្យបានកាន់តែឆាប់រហ័ស។

[12] មាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

# ជំពូកទី២
# ការស៊ើបសួរ

# ជំពូកទី២

# ការស៊ើបសួរ

## ២.១ កិច្ចរបស់ចៅក្រមស៊ើបសួរ

បើយោងទៅតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាយើង បន្ទាប់ពីមានការ បើកការស៊ើបសួរហើយនោះ ចៅក្រមស៊ើបសួរមានតួនាទីជាបន្តបន្ទាប់ទៀតត្រូវបំពេញ ដែលកិច្ចទាំងនោះមានដូចជាការឆែកឆេរ ចាប់យកវត្ថុតាង និង ការធ្វើកោសលវិច័យ។ល។ ដែលជាកិច្ចរបស់ចៅក្របស៊ើបសួរ ត្រូវបំពេញនាដំណាក់កាលនៃការស៊ើបសួរ។

យុត្តាធិការស៊ើបសួរ គឺជាដំណាក់កាលមួយនៃវិធានការស្រាវជ្រាវរបស់ចៅក្រមដែលមានតួនាទីក្នុងការស្វែងរកនូវភស្តុតាងដាក់បន្ទុក និងដោះបន្ទុក [13] ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាច និងសិទ្ធិ ឱ្យទៅចៅក្រមស៊ើបសួរនូវអំណាចជាច្រើន។ ហើយការស៊ើបសួរនេះផងដែរ ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីម្នាក់អមជានិច្ច [14] ។ ប៉ុន្តែ ក្នុងករណីណាក៏ដោយ ក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ។

### ២.១.១ ការសម្ងាត់នៃការស៊ើបសួរ

ជាទូទៅការស៊ើបសួរត្រូវតែធ្វើជាសម្ងាត់ [15] និយាយជារួមបុគ្គលដែលបានចូលរួមក្នុងដំណាក់កាល នៃការស៊ើបសួរជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ អ្នកបកប្រែ គ្រូពេទ្យ ត្រូវតែ ប្រកាន់ភ្ជាប់នូវគោលការណ៍សម្ងាត់ មិនត្រូវទម្លាយរឿងដែលជាអាថកំបាំងនៃដំណើរការរឿងក្តី ជាសាធារណៈ ឬទៅកាន់អ្នកជិតដិតណាមួយឱ្យដឹងពីអាថកំបាំងនៃនីតិវិធីឡើយ។

ការបំពានលើការសម្ងាត់ ដែលបានប្រព្រឹត្តផ្ទុយដោយបានទម្លាយនូវអាថកំបាំងនៃកិច្ចស៊ើបសួរ គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។ ប៉ុន្តែព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយមិនពិត ដោយគ្មានទោសផងដែរ ព្រោះវាជាផលប្រយោជន៍នៃរឿងក្តីទៅវិញ និងជាការការពារសិទ្ធិដល់ភាគីនៅក្នុងរឿងក្តី។

---

[13] មាត្រា១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[14] មាត្រា១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[15] មាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ២.១.២ សមត្ថកិច្ចដែនដី

សមត្ថកិច្ចដែនដី[16]របស់ចៅក្រមស៊ើបសួរមានដូចតទៅ៖

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមច្រើនរូបនៅសាលាដំបូងផ្សេងៗគ្នា នៅក្នុងរឿងព្រហ្មទណ្ឌតែមួយ ត្រូវបញ្ជូនទៅសភាស៊ើបសួរនៅសាលាឧទ្ធរណ៍ជាអ្នកសម្រេច។

ក្នុងករណីដែលមានទំនាស់ រវាងសភាស៊ើបសួរច្រើនដែលអមនៅសាលាឧទ្ធរណ៍ផ្សេងគ្នា នៅក្នុងរឿងក្តីព្រហ្មទណ្ឌតែមួយ ត្រូវសម្រេចដោយប្រធានតុលាការកំពូល ហើយសេចក្តីសម្រេចនេះគឺបិទផ្លូវ តវ៉ា។

### ២.១.៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដែលចេញឱ្យចៅក្រមស៊ើបសួរ ដើម្បីបើកការស៊ើបសួរនោះ គឺអាចបើកប្រឆាំង និងបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលបង្ហាញ ប្រាប់ឈ្មោះ នៅក្នុងដីកាប្រសិនបើកំណត់អត្តសញ្ញាណជននោះបាន ប្រឆាំងនឹងអញ្ញាតជន ប្រសិនបើមិនស្គាល់អត្តសញ្ញាណ។

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណា មួយដោយគ្មានវត្តមានដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានឡើយ ពោលគឺបើមិនមានដីកានេះទេគឺចៅក្រមស៊ើបសួរមិនមានសិទ្ធបើកការស៊ើបសួរដោយឯកឯងបានឡើយ [17]។

ក្នុងករណីមួយទៀត កាលណាបើចៅក្រមស៊ើបសួរ ទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីនោះ ចៅក្រមស៊ើបសួររូបនោះ ត្រូវតម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ប្រាក់តម្កល់[18]ទុកជាមុនសិន។ ក្រោយពីបានទទួលពាក្យបណ្តឹងសាមញ្ញនេះរួចចៅក្រមស៊ើបសួរ ក៏ពុំអាចទាន់បើកការស៊ើបសួរបានដែរ គឺចៅក្រមស៊ើបសួររូបនោះត្រូវបញ្ជូនពាក្យបណ្តឹងសាមញ្ញនោះ ឱ្យទៅ ព្រះរាជអាជ្ញាដើម្បីសុំឱ្យព្រះរាជអាជ្ញារូបនោះចេញដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដើម្បីបើកការស៊ើបសួរដោយអនុលោមតាមមាត្រា១៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[16] មាត្រា១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[17] មាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[18] មាត្រា១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ២.១.៤ វិសាលភាពនៃការប្ដឹង

ក្រោយពីទទួលដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញារួច ចៅក្រមស៊ើបសួររូបនោះ ត្រូវស៊ើបសួរ តែអំពីអង្គហេតុ នោះតែប៉ុណ្ណោះ។ ប្រសិនបើមានលេចចេញអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌក្នុងអំឡុងពេល នៃការស៊ើបសួរនោះ ចៅក្រមស៊ើបសួរនោះត្រូវបញ្ជូនអង្គហេតុថ្មីនោះទៅព្រះរាជអាជ្ញាឱ្យបានដឹងជាមុនសិន គឺមិនអាចបើកការស៊ើបសួរដោយខ្លួនឯងបានទៅលើអង្គហេតុថ្មីនោះបានឡើយ។ ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែមទេ[19] ប្រសិនបើអង្គហេតុថ្មីនោះ គ្រាន់តែជាស្ថានទម្ងន់ទោស នៃអង្គហេតុចាស់ ពោលគឺលុះត្រាតែអង្គហេតុថ្មីនោះ ជាអង្គហេតុថ្មីសុទ្ធសាធ ទើបត្រូវការដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាថ្មីមួយទៀត។

### ២.១.៥ ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា

កាលណាចៅក្រមស៊ើបសួរទទួលពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវបញ្ជូនបណ្ដឹង[20]នេះទៅព្រះរាជអាជ្ញា។ ដើម្បីផ្ដល់ភាពងាយស្រួលក្នុងការស្វែងយល់ពីការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញានេះ យើងឃើញមានការជាប់ពាក់ព័ន្ធទៅនឹងភាគីជនរងគ្រោះ ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានចាត់ទុកថាជាដើមបណ្ដឹងរដ្ឋប្បវេណី មានន័យថា ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម អាចដាក់ពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដោយមានអានុភាពប្ដឹងដល់ចៅក្រមស៊ើបសួរ ចំពោះបណ្ដឹងអាជ្ញា។

ដោយមានការដាក់ពាក្យបណ្ដឹងចំពោះការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់បណ្ដឹង តាមដីកា មុននឹងបញ្ជូនបណ្ដឹងនេះទៅកាន់ព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាអាចធ្វើការប្ដឹងទៅកាន់ចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលដីកានេះ ធ្វើការប្រឆាំងនឹងអញ្ញាតជនប៉ុណ្ណោះ បើទោះបីជាបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានកំណត់ទៅលើឈ្មោះបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។ ជាងនេះទៅទៀតព្រះរាជអាជ្ញាក៏អាចស្នើសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនបើបណ្ដឹងអាជ្ញាត្រូវបានផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌនោះទេ។

ក្នុងករណីនេះដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ បើចៅក្រមស៊ើបសួរនៅតែស៊ើបសួរ គឺត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ ប៉ុន្តែបើទោះបីជាការសម្រេច

[19] មាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[20] មាត្រា១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

របស់ចៅក្រមស៊ើបសួរយ៉ាងណាក៏ដោយ ក៏ចៅក្រមស៊ើបសួរនៅតែមិនអាចស៊ើបសួរបានដដែរ ប្រសិនបើព្រះរាជអាជ្ញាមិនបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ។

## ២.២ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

### ២.២.១ ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ

ចៅក្រមស៊ើបសួរ ត្រូវតែដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ នូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យនូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ ចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះឱ្យស្ថិតក្រោមការពិនិត្យ ក្នុងឋានៈជា ចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិត[21]។

#### ២.២.១.១ បុគ្គលដែលអាចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ

ចៅក្រមស៊ើបសួរ វាយតម្លៃអំពីកាលានុវត្តភាព[22]នៃការជូនដំណឹងពីការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យជាយថាហេតុបន្ទាប់ពីបានធ្វើការស៊ើបសួរចាំបាច់ផ្សេងៗរួចមក។

យើងសង្កេតឃើញថា ចៅក្រមស៊ើបសួរត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិនូវការគ្មានលទ្ធភាពក្នុងការសួរយកចម្លើយលើបុគ្គលដែលមានតម្រុយពិរុទ្ធភាពក្នុងឋានៈជាសាក្សី [23] ។ ការបញ្ញត្តិបែបនេះ គឺរក្សានូវការគោរពសិទ្ធិមនុស្ស ដែលអាចត្រូវបំពានយ៉ាងធ្ងន់ធ្ងរដោយកិច្ចស៊ើបសួរ ដែលជាគោលការណ៍ជនត្រូវចោទមានសិទ្ធិក្នុងការពឹងពាក់មេធាវីដើម្បីការពារសិទ្ធិរបស់ខ្លួន។ ក្រោយពីនេះបុគ្គលដែលត្រូវបានកំណត់ឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរអាចសួរចម្លើយបានតែក្នុងឋានៈជាជនត្រូវចោទតែប៉ុណ្ណោះ។

ដោយឡែកការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យធ្វើឡើងនៅពេលដែលជនពាក់ព័ន្ធចូលបង្ហាញខ្លួនដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរ។ បែបបទនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យមានក្នុងមាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានចែងថា៖ នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ដែលប្រាប់ជននេះឱ្យបានដឹងពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬ មិនឆ្លើយបានដោយសេរី។ និទ្ទេសស្ដីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។ ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើប

[21] មាត្រា១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[22]កាលានុវត្តភាព ជាគោលការណ៍សម្រាប់អង្គអយ្យការធ្វើការពិចារណាមុនចំណាត់ការនីតិវិធី

[23] មាត្រា ១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សួរត្រូវទទួលចម្លើយនោះភ្លាម។ ចៅក្រមស៊ើបសួរត្រូវប្រាប់ជនត្រូវចោទ ឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬ ក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដោយអនុលោមតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។

ជាលក្ខណៈពិសេស ប្រសិនបើជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។

ក្រោយពីការចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួររួចមក ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាស័យដ្ឋានរបស់ខ្លួន។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថាៈ

- ខ្លួនត្រូវតែជូនពត៌មានដល់ចៅក្រមស៊ើបសួរនៅពេលណាដែលខ្លួនផ្លាស់ប្ដូរអាស័យដ្ឋាន
- គ្រប់ការឱ្យដំណឹងដែលបានធ្វើឡើងតាមអាស័យដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនត្រូវចោទនោះត្រូវចាត់ទុកថាធ្វើឡើងដល់សាមីខ្លួនផ្ទាល់។

ការឱ្យដំណឹងព្រមទាំងការប្រកាសស្ដីពីការផ្លាស់ប្ដូរអាស័យដ្ឋាន ត្រូវចុះក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។ ជនត្រូវចោទអាចត្រូវបានទទួលជំនួយនៃការបកប្រែ ពីអ្នកបកប្រែ ដែលអ្នកបកប្រែត្រូវស្បថតាមជំនឿសាសនារបស់ខ្លួន ថានឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយរបស់ជនត្រូវចោទ។

### ២.២.១.២ អានុភាពនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ

បុគ្គលដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យរបស់តុលាការ នោះបុគ្គលនឹងទទួលបានឋានៈជាជនត្រូវចោទ ដែលក្លាយខ្លួនទៅជាភាគីនៃសំណុំរឿងក្ដីព្រហ្មទណ្ឌ។ សិទ្ធិរបស់ជនត្រូវចោទ មានសិទ្ធិការពារខ្លួនដែលស្ដែងឡើងតាមសិទ្ធិទទួលបាននូវជំនួយមេធាវីតាមលក្ខន្តិកៈមេធាវី សិទ្ធិចូលរួមក្នុងការការពារខ្លួន ដោយឆ្លើយ ឬមិនឆ្លើយ សិទ្ធិត្រូវបានស្ដាប់ដោយចៅក្រម និងមិនមែនដោយមន្ត្រីនគរបាលយុត្តិធម៌ សិទ្ធិទទួលព័ត៌មានពីសកម្មភាពខាងផ្នែកតុលាការរបស់ចៅក្រមស៊ើបសួរ សិទ្ធិសុំមោឃភាពនីតិវិធីសិទ្ធិចូលរួមយ៉ាងសកម្មក្នុងដំណើរការស៊ើបសួរដែលសុំទៅឱ្យចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវមួយចំនួនជាអាទិ៍។ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរ ធ្វើការសួរចម្លើយខ្លួន ស្ដាប់ចម្លើយភាគីរដ្ឋប្បវេណី ឬ សាក្សី ធ្វើការសួរចម្លើយតទល់ ឬចុះទៅទីកន្លែងណាមួយ។ ការស្នើសុំនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុដែលអនុញ្ញាតឱ្យបញ្ជាក់ពីប្រយោជន៍របស់វា។

### ២.២.២ ការសួរចម្លើយជនត្រូវចោទ

ជាធម្មតាជនត្រូវចោទគឺត្រូវបានសួរចម្លើយដោយចៅក្រមស៊ើបសួរនា ដំណាក់កាលស៊ើបសួរ និងទទួលយកចម្លើយនោះមកធ្វើជាកម្មវត្ថុនៃការថ្លឹងថ្លែងកិច្ចប្រតិបត្តិការណ៍នៃការស៊ើបសួរក្នុងការ ស្វែងរក

ភស្តុតាងដាក់ បន្ទុក និងដោះបន្ទុកជូនភាគីក្តីទាំងសងខាង។ ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរអាចស្វែងរកអ្នកបកប្រែ[24]។

### ២.២.២.១ វត្តមានរបស់មេធាវីក្នុងពេលសួរចម្លើយជនត្រូវចោទ

កាលណាជនត្រូវចោទ មានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីនោះយ៉ាងតិចបំផុត ៥ថ្ងៃមុនការសួរចម្លើយ ណាមួយគឺគេចង់ទុកថេរវេលានេះជូនដល់មេធាវីក្នុង ការពិនិត្យមើលសំណុំរឿងឱ្យបាន គ្រប់ជ្រុងជ្រោយមុននឹងចៅក្រមស៊ើបសួរ សួរចម្លើយកូនក្តីរបស់ខ្លួន។

មួយវិញទៀត ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅតែចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលគេបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរ អាចសួរសំណួរជនត្រូវចោទដោយគ្មានវត្តមានរបស់មេធាវីនោះបាន។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ អាចសួរសំណួរជនត្រូវចោទ ដោយមិនចាំបាច់កោះហៅ មេធាវីក៏ បានដែរប្រសិនបើជនត្រូវចោទបានបោះបង់សិទ្ធិយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន។

ក៏ប៉ុន្តែក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយជនត្រូវចោទដោយ មិនមានវត្តមាន របស់មេធាវីក៏បានដែរ ដែលភាពបន្ទាន់នេះត្រូវតែបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យ ខ្លាចបាត់បង់តម្រុយនៃភស្តុតាង។

### ២.២.២.២ សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ

នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកសំណួរបានដែរ ដោយមានការអនុញ្ញាតពីសំណាក់ចៅក្រមស៊ើបសួរ ក៏ប៉ុន្តែក្នុងករណី មិនអនុញ្ញាតឱ្យសួរត្រូវចុះក្នុងកំណត់ហេតុ។

មេធាវីរបស់ជនត្រូវចោទ ដែលកំពុងជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយ កូនក្តីរបស់ខ្លួន បានគ្រប់ពេល មិនថានៅក្រៅ ឬក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនក្តី។ ដែលការសន្ទនានេះមិនអាចត្រូវគេស្តាប់ ឬថតបានឡើយ គឺមេធាវី មិនអាចឱ្យ លិខិតចតចម្លង នៃសំណុំរឿងដល់កូនក្តីរបស់ខ្លួនបានឡើយ។

### ២.២.២.៣ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី

ដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីក្នុងរឿងព្រហ្មទណ្ឌដូចជាជនត្រូវចោទដែរហើយគាត់ក៏មានសិទ្ធក្នុងការរកមេធាវីដើម្បីជួយការពារក្តីឱ្យខ្លួនបានដូចជាជនត្រូវចោទដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិពិសេសមួយ ត្រង់ថានៅក្នុងដំណាក់កាលនៃការស៊ើបសួរ ចៅក្រមស៊ើបសួរមានសិទ្ធិត្រឹមតែស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ [25]គឺខុសពីជនត្រូវចោទដែលចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទបាន។

---

[24] មាត្រា១៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[25] ១៥០ នៃនីតិវិធីព្រហ្មទណ្ឌ

ចំពោះសាក្សីវិញ គឺជាបុគ្គលដែលនៅក្រៅអង្គហេតុនិងអាចផ្តល់ព័ត៌មានដែលមានប្រយោជន៍ ដើម្បីបង្ហាញការពិតទៅចៅក្រមស៊ើបសួរ មួយវិញទៀត នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ចៅក្រមស៊ើបសួរ អាចកោះហៅជនទាំងឡាយដែលបានដឹងអំពីអង្គហេតុដែលបានកើតឡើង ក្នុងឋានៈជាសាក្សីដើម្បីធ្វើការ ស្តាប់ចម្លើយ[26] ដូចដែលធ្វើចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែរ។

**២.២.៣ ការឆែកឆេរ និងការចាប់យកវត្ថុតាង**

**២.២.៤.១ ការឆែកឆេរ**

ផ្ទុយពីគំនិតដែលទទួលបានជារួម ការស៊ើបសួរមិនអនុញ្ញាតឱ្យធ្វើការឆែកឆេរគ្រប់កន្លែងដោយពុំមានលក្ខខណ្ឌដូចក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែងនោះទេ។ ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរនេះ ការឆែកឆេរត្រូវគោរពតាមម៉ោង ដែលមិនអាចចាប់ផ្តើមឆែកឆេរមុនម៉ោង **៦ ព្រឹក** និងក្រោយម៉ោង **១៨ ល្ងាច**បានទេ លើកលែងតែករណីឆែកឆេរកន្លែងបើកឱ្យសាធារណជនដូចជាកន្លែងលក់ និង ប្រើប្រាស់គ្រឿងញៀន។ ដូចគ្នានេះដែរ ការឆែកឆេរការិយាល័យមេធាវីត្រូវធ្វើឡើងដោយមានវត្តមានប្រធានគណៈមេធាវី ឬប្រតិភូរបស់គាត់[27]។

អ្នកកាន់កាប់កន្លែងត្រូវមានវត្តមាន ប្រសិនបើគ្មានអ្នកកាន់កាប់ទេ ត្រូវមានសាក្សីពីរនាក់ដែលបានចាត់តាំងដោយចៅក្រមស៊ើបសួរដែលសាក្សីនោះមិនអាចជាអាវុធហត្ថ ឬនគរបាល។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ដែលត្រូវមានចុះហត្ថលេខាអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សីនីមួយៗ និងជាយថាហេតុ អត្តសញ្ញាណរបស់ប្រធានគណៈមេធាវី ឬប្រតិភូរបស់គាត់។ជាចុងក្រោយកំណត់ហេតុនេះត្រូវមានចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។

**២.២.៤.២ ការចាប់យកវត្ថុតាង**

ច្បាប់អនុញ្ញាតឱ្យចៅក្រមស៊ើបសួរចាប់វត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាង។ នៅក្រោយពីបានបង្ហាញវត្ថុដែលចាប់ដល់អ្នកកាន់កាប់ទីកន្លែង ឬ ដល់សាក្សីទាំងពីរនាក់រួចមក ចៅក្រមស៊ើបសួរធ្វើកំណត់ហេតុស្តីពីការចាប់ ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក។ កំណត់ហេតុស្តីការចាប់នេះត្រូវមានការចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីរួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សី ពីរនាក់។ កំណត់ហេតុត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ[28]។

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ចៅក្រមស៊ើបសួរមានអំណាចប្រគល់វត្ថុដែលចាប់យកនោះវិញ។ ចៅក្រមស៊ើបសួរអាចធ្វើដោយឯកឯងបន្ទាប់ពីមានយោបល់ពីព្រះរាជអាជ្ញា ឬតាមរយៈដីកាសន្និដ្ឋានរបស់

[26] ១៥៣ នៃនីតិវិធីព្រហ្មទណ្ឌ

[27] ១៥៩ នៃនីតិវិធីព្រហ្មទណ្ឌ

[28] មាត្រា១៦០ នៃនីតិវិធីព្រហ្មទណ្ឌ

ព្រះរាជអាជ្ញា ឬដោយមានការស្នើសុំពីគូភាគី ឬគ្រប់បុគ្គលទាំងអស់ដែលអះអាងថាមានសិទ្ធិលើវត្ថុដែលចាប់។ ហើយគាត់ក៏អាចបដិសេធប្រគល់សងវត្ថុចាប់យក ដោយផ្អែកទៅលើមូលហេតុដែលបានរៀបរាប់ដោយច្បាប់។ នៅពេលដែលការប្រគល់សងជាឧបសគ្គដល់ការសម្តែងឱ្យឃើញការពិតនៅពេលវត្ថុមានគ្រោះថ្នាក់ដល់បុគ្គល ឬ ទ្រព្យសម្បត្តិ និងនៅពេលដែលវត្ថុត្រូវបានកាន់កាប់ដោយខុសច្បាប់ ចៅក្រមស៊ើបសួរចេញសេចក្តីសម្រេចដែលទាក់ទងនឹងការប្រគល់វត្ថុចាប់យក តាមរយៈដីកាដែលមានសំអាងហេតុដែលបើកផ្លូវបណ្តឹងតវ៉ា។

### ២.២.៤ កោសលវិច័យ

នៅក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬ តាមពាក្យសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី[29]។ ហើយកាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ តាមការស្នើសុំនេះផងដែរចៅក្រមស៊ើបសួរ និងចេញដីកាសម្រេច ក្នុងរយៈពេល **៥ ថ្ងៃ** ប្រសិនបើពាក្យសុំនោះធ្វើដោយព្រះរាជអាជ្ញា។ រយៈពេល **១ ខែ** ប្រសិនបើពាក្យសុំនោះធ្វើដោយជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ដែលដីកាសម្រេចនេះត្រូវជូនដំណឹងឱ្យដល់អ្នកប្តឹងសុំជាបន្ទាន់។

ចំពោះអ្នកជំនាញត្រូវបានចាត់តាំងដោយចៅក្រមស៊ើបសួរដែលអាចមាន ១ រូប ឬ ច្រើនរូប ស្ថិតនៅក្រោមការត្រួតពិនិត្យដោយចៅក្រមស៊ើបសួរ និងអ្នកជំនាញត្រូវធ្វើរបាយការណ៍អំពីការធ្វើកោសលវិច័យជូនចៅក្រមស៊ើបសួរ។ សម្រាប់សោហ៊ុយដែលបានចំណាយចំពោះការធ្វើកោសលវិច័យនោះគឺក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការបែងចែកចំពោះការចំណាយលើកោសលវិច័យដូចជា បើកោសលវិច័យកើតចេញពីការសុំរបស់ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ជាសោហ៊ុយរបស់អ្នកស្នើសុំ។ ប្រសិនកោសលវិច័យកើតចេញពីចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា នគរបាលយុត្តិធម៌ ជាសោហ៊ុយរបស់រដ្ឋ។

### ២.២.៥ ការស្តាប់ទូរស័ព្ទ

ចំពោះការស្តាប់ទូរស័ព្ទ ក៏ជាកិច្ចមួយយ៉ាងពិសេសសំរាប់ចៅក្រមស៊ើបសួរអនុវត្ត កិច្ចនេះដើម្បី ស្វែងរកការពិតដោយអនុលោមតាមច្បាប់។ ពីព្រោះសព្វថ្ងៃនេះបច្ចេកវិទ្យា កាន់តែទំនើបដូច្នោះការទាក់ទងគ្នា ក៏មានការឆាប់រហ័សយ៉ាងគួរឱ្យកក់សម្គាល់ តួយ៉ាងដូចជាការទាក់ទងគ្នាតាមទូរស័ព្ទ ឬតាមបណ្តាញសង្គម នានាជាដើមអញ្ចឹងហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌរបស់យើងបានដាក់បញ្ចូលការស្តាប់ទូរស័ព្ទរបស់ភាគីក្នុងរឿងក្តី ដោយចៅក្រមស៊ើបសួរ និងដើម្បីធានាក្នុងការស្វែងរកឱ្យឃើញការពិតក្នុងការរកយុត្តិធម៌ជូនដល់បុគ្គលដែលស្លូតត្រង់។

[29] មាត្រា១៦២ កថាខណ្ឌទី១ នៃនីតិវិធីព្រហ្មទណ្ឌ

### ២.២.៦.១ ការស្តាប់ទូរស័ព្ទដែលបង្គាប់ដោយចៅក្រមស៊ើបសួរ

តាមតម្រូវការចាំបាច់ដើម្បីស្តែងឱ្យឃើញការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យស្តាប់និងថតការធ្វើការសន្ទនាតាមទូរស័ព្ទ និងតាមមធ្យោបាយទូរគមនាគមន៍[30] ដូចជាៈ សារតាមទូរស័ព្ទ ឬសារអ៊ីនធើណេត។

ចៅក្រមស៊ើបសួរ ក៏អាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញ តាំងឧបករណ៍បច្ចេកទេសជំនាញផ្នែកនេះដើម្បីធ្វើការថតនេះបានដែរ មិនតែប៉ុណ្ណោះចៅក្រមស៊ើបសួរត្រូវបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងដែលគោលដៅត្រូវចាប់ និងត្រូវកំណត់ផងដែរអំពីរយៈពេល នៃបេសកកម្មនោះ។

កាលណាបើបេសកកម្ម ត្រូវបានបំពេញរួចរាល់ហើយ អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការនោះ ត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសម្លេងដែលថតបាន។ ការធ្វើជាលាយលក្ខណ៍អក្សរនេះត្រូវឆ្លុះបញ្ចាំង យ៉ាងត្រឹមត្រូវនៃសម្លេងដែលថតបាន ហើយសម្លេងដែលថតបាននេះត្រូវប្រគល់ជូនចៅក្រមស៊ើបសួរនិងបិទស្លាក។ ក្នុងកិច្ចការនេះដែរចៅក្រមស៊ើបសួរអាចចេញដីកាចាត់ឱ្យស៊ើបសួរជំនួសបានផងដែរ។

### ២.២.៦ ដីកាចាត់ឱ្យស៊ើបសួរជំនួស

តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធឱ្យចៅក្រម នៃតុលាការរបស់ខ្លួនដែលខ្លួនតាំងនៅ តុលាការផ្សេង ទៅមន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរជំនួសនេះ។

### ២.២.៧.១ អត្ថន័យនៃដីកាចាត់ឱ្យស៊ើបសួរជំនួស

ដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវបញ្ជាក់អំពីកិច្ចដែលត្រូវធ្វើ ចំពោះកិច្ចនេះត្រូវតែមាន ទំនាក់ទំនង ដោយផ្ទាល់ជាមួយបទល្មើស ដែលចោទប្រកាន់។ ដីកាចាត់ឱ្យស៊ើបសួរជំនួសមិន អាចមានលក្ខណៈជាទូទៅ បានទេ ពោលគឺការស៊ើបសួរជំនួសនេះគឺត្រូវ គោរពតាមគោលការណ៍ដែលចៅក្រមស៊ើបសួរដើមបានកំណត់ តាមដីកាដែលបានកំណត់។

ចៅក្រមស៊ើបសួរ កំណត់ចិរវេលា [31] ដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ ដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវមានកាលបរិច្ឆេទ ចុះហត្ថលេខា ដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង មិនតែប៉ុណ្ណោះ ចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា។ កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានចេញ ឱ្យដល់ចៅក្រមណាម្នាក់ ចៅក្រមរូបនោះប្រើប្រាស់ អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ ពោលគឺចៅក្រមដែលទទួលដីកាចាត់ឱ្យស៊ើបសួរជំនួសប្រើប្រាស់សិទ្ធិ ដូចចៅក្រមដើមចេញដីកាឱ្យដែរ។ លើកលែងតែការ

---

[30] មាត្រា១៦០ នៃនីតិវិធីព្រហ្មទណ្ឌ

[31] មាត្រា១៦០ នៃនីតិវិធីព្រហ្មទណ្ឌ

ចាត់ឱ្យស៊ើបសួរជំនួស បានចេញឱ្យទៅមន្ត្រីនគរបាលយុត្តិធម៌ ពោលគឺគេបានកម្រិតសិទ្ធិខ្លះ និងព្រំដែនចំពោះគាត់មិនដូចចៅក្រមឱ្យទៅចៅក្រមឡើយ។

**២.២.៧.២ ដីកាចាត់ឱ្យស៊ើបសួរជំនួសចំពោះនគរបាលយុត្តិធម៌**

មានតែមន្ត្រីនគរបាលយុត្តិធម៌ ដូចជា នគរបាល ឬ អាវុធហត្ថ ប៉ុណ្ណោះ ដែលអាចទទួលបាននូវការផ្ទេរអំណាច ឬដីកាចាត់ឱ្យស៊ើបសួរជំនួស។ ចៅក្រមស៊ើបសួរអាចចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងគ្រប់មន្ត្រីនគរបាលយុត្តិធម៌លើដែនដីប្រទេសទាំងមូល។ មន្ត្រីនគរបាលយុត្តិធម៌នេះស្ថិតនៅក្រោមអំណាចផ្ទាល់របស់ចៅក្រមស៊ើបសួរ ក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។

ប៉ុន្តែចៅក្រមស៊ើបសួរមិនអាចផ្ទេរអំណាចមួយចំនួនរបស់ខ្លួនបានទេ។ អំណាចដែលមិនអាចត្រូវបានផ្ទេរទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌ គឺជា អំណាចសួរចម្លើយជនត្រូវចោទ ឬ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី [32]។ អំណាចសួរតទល់បុគ្គលខាងលើជាមនុស្សផ្សេងទៀត អំណាចចេញដីកា ឬ ធ្វើការឆែកឆេរក្នុងកន្លែងដែលការពារ។ អំណាចដែលអាចផ្ទេរបានគឺៈ

- ស្តាប់ចម្លើយសាក្សី បើក្នុងពេលស្តាប់ចម្លើយ បានលេចចេញនូវតម្រុយនៃពិរុទ្ធភាពប្រឆាំងនឹងសាក្សីការស្តាប់ចម្លើយត្រូវបញ្ចប់ ដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌ផ្តល់ដំណឹងភ្លាមទៅចៅក្រមស៊ើបសួរ។
- ការឆែកឆេរ និងការចាប់យកវត្ថុ ដោយគោរពលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៥៩ និង មាត្រា ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ការឃាត់ខ្លួន អំណាចត្រួតពិនិត្យដែលធ្វើដោយព្រះរាជអាជ្ញាក្នុងក្របខណ្ឌនៃការស៊ើបអង្កេតតាមផ្លូវតុលាការត្រូវធ្វើដោយចៅក្រមស៊ើបសួរនៅពេលឃាត់ខ្លួនក្នុងក្របខណ្ឌនៃការចាត់ឱ្យស៊ើបសួរជំនួស។
- ការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទ និងការចាត់ការឆ្លងឆ្លើយតាមមធ្យោបាយទូរគមនាគមន៍។

ជាការពិតណាស់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីអំពីគ្រប់កិច្ចដែលបំពេញដោយអនុវត្តតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលត្រូវប្រគល់ឱ្យចៅក្រមស៊ើបសួរដើម្បីបញ្ចូលក្នុងសំណុំរឿងនៅពេលដែលកិច្ចត្រូវបានបំពេញចប់។

[32] មាត្រា១៨០ នៃនីតិវិធីព្រហ្មទណ្ឌ

# ជំពូក៣
# វិធានការនិរន្តរាយ

# ជំពូក៣
# វិធានការនិរន្តរាយ

## ៣.១ ដីកា

ជាធម្មតាសេចក្តីសម្រេចទាំងឡាយ ដែលចេញនៅគ្រប់ដំណាក់កាលនៃរឿងក្តីព្រហ្មទណ្ឌមិនថា ចេញដោយចៅក្រមក្តី ដោយព្រះរាជអាជ្ញាក្តី ហៅថាដីកា ដែលដីកាទាំងអស់នោះ រួមមានដូចជា៖ ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបញ្ជូនរឿងឱ្យស៊ើបសួរជាដើម។ល។

ចៅក្រមស៊ើបសួរ មានអំណាចក្នុងការចេញដីកា ទាំងឡាយព្រមទាំងអាចកេនកងកម្លាំងសាធារណៈ ដើម្បីអនុវត្តដីកាដែលចេញដោយចៅក្រមស៊ើបសួររូបនេះ ហើយប្រសិនបើជនណាម្នាក់មានការ រឹងទទឹងក្នុងការចូលរួមអនុវត្តនីតិវិធី ដែលក្នុងនោះមានដូចជា សាក្សី ជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាព គឺចៅក្រមស៊ើបសួរអាចធ្វើការចាប់បង្ខំអោយជនទាំងឡាយនោះចូលខ្លួន ដោយប្រើប្រាស់ កងកម្លាំងសាធារណៈ។

### ៣.១.១ ដីកាបង្គាប់ឱ្យចូលខ្លួន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យចូលខ្លួននេះដែរ គឺជាបញ្ជាដល់ បុគ្គលណាម្នាក់ឱ្យចូលខ្លួន និងទៅបង្ហាញខ្លួននៅមុខ ចៅក្រមស៊ើបសួរ ពោលគឺ ចេញដើម្បីកោះហៅទៅលើបុគ្គលទាំងឡាយដែលមានតម្រុយពីពិរុទ្ធភាពនិងមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើង គឺដើម្បីដំណើរការល្អក្នុងដំណាក់កាលនៃការស៊ើបសួរ ឬដើម្បីស្វែងរកភស្តុតាង ដាក់បន្ទុក និងដោះបន្ទុក ជូនគូរភាគីទាំងសងខាង។

ចំពោះនិទ្ទេសដែលត្រូវ ចុះលើដីកាបង្គាប់ឱ្យចូលខ្លួននេះមានដូចតទៅ៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ អត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមស៊ើបសួរដែលចេញដីកា

ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[33]។

#### ៣.១.១.១ ការជូនដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួន ត្រូវឱ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា ពោលគឺពួកគាត់ជាអ្នករត់ដីកា។

[33] មាត្រា១៨៧ នៃនីតិវិធីព្រហ្មទណ្ឌ

បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា និងត្រូវចុះហត្ថលេខាទៅលើដើមដីកា ដើម្បីឱ្យ អ្នកប្រគល់ដីកា យកដើមដីកាជូនចៅក្រមស៊ើបសួរវិញ។

មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលាត្រូវជូនដំណឹងដល់ ចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកម្មរបស់ខ្លួន។

### ៣.១.២ ដីកាបង្គាប់ឱ្យនាំខ្លួន

ដីកានេះ គឺជាបញ្ជាដែលមានលក្ខណៈបង្ខំ ដែលបង្គាប់ដល់កងកម្លាំងសាធារណៈឱ្យចាប់ខ្លួន និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ[34]។ ដីកាបង្គាប់ឱ្យនាំខ្លួន អាចចេញទៅបានតែទៅលើជនត្រូវចោទ ឬទៅលើបុគ្គលដែលមានតម្រុយពីពិរុទ្ធភាពតែប៉ុណ្ណោះ។ ជាងនេះទៅទៀត ដីកាបង្គាប់ឱ្យនាំខ្លួននេះផងដែរ មាននិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។

#### ៣.១.២.១ ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន

ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌[35] ដែលមានកាតព្វកិច្ចនាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅចំពោះមុខ ចៅក្រមស៊ើបសួរ ក្រោយពេលចាប់ខ្លួនបាន។ ប៉ុន្តែក្នុងករណីដែលចៅក្រមស៊ើបសួរមិនអាចសួរចម្លើយជននោះភ្លាមៗ ឬដោយមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរបានភ្លាមៗទេ ដីកានេះ បានអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌នាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅរក្សាទុកនៅ អង្គភាពក្នុងមណ្ឌលឃុំខ្លួន ឬពន្ធនាគារបានដែលមានថិរវេលាមិនអាចលើសពី ១ថ្ងៃបានឡើយ ពោលគឺត្រូវតែនាំខ្លួនបុគ្គលដែលពាក់ព័ន្ធនេះ ទៅចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួសយ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់។ ផ្ទុយពីនេះប្រសិនបើជាការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលដែលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។ ប្រការមួយទៀតដែលត្រូវជៀសវាងដាច់ខាត ដើម្បីកុំឱ្យមានការរំលោភសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិធម៌ដែលអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន មិនអាចចូលទៅក្នុងលំនៅដ្ឋានរបស់បុគ្គលដែលពាក់ព័ន្ធមុន ម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ បានទេ។

[34] មាត្រា១៩០ នៃនីតិវិធីព្រហ្មទណ្ឌ

[35] មាត្រា១៩២ នៃនីតិវិធីព្រហ្មទណ្ឌ

ក្នុងករណីចុងក្រោយនេះ ប្រសិនបើបុគ្គលត្រូវនាំមកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរត្រូវបានឃុំខ្លួនបណ្តោះអាសន្ននោះថិរវេលានៃការឃុំខ្លួននេះ ត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននោះដែរ។

**កំណត់សម្គាល់៖** អនុលោមតាមបទបញ្ញត្តិច្បាប់ចាស់* ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនបានចំពោះសាក្សីដែលរឹងទទឹងមិនព្រមចូលខ្លួនតាមការកោះហៅ ប៉ុន្តែតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដែលបានអនុវត្តនាពេលបច្ចុប្បន្ន នៅក្នុងក្របខណ្ឌនៃការចេញដីកាបង្គាប់ឱ្យនាំខ្លួនចៅក្រមស៊ើបសួរត្រូវបានកម្រិតទុកជាស្រេច ដែលមានសិទ្ធិអំណាចក្នុងការចេញដីកាប្រភេទនេះបានតែទៅលើជនត្រូវចោទ និងបុគ្គលដែលមានតម្រុយពីពិរុទ្ធភាពតែប៉ុណ្ណោះ មានន័យថាចៅក្រមស៊ើបសួរពុំអាចចេញដីកានេះចំពោះសាក្សីបានឡើយ ប៉ុន្តែមិនមែនមានន័យថា ចៅក្រមស៊ើបសួរពុំមានអំណាច ក្នុងការបង្ខំឱ្យសាក្សីបង្ហាញនោះទេ។ កាលបើសាក្សី ណាម្នាក់ដែលចៅក្រមស៊ើបសួរយល់ឃើញថាមានប្រយោជន៍ក្នុងការសម្តែងឱ្យឃើញការពិត ហើយរឹងទទឹងមិនព្រមចូលបង្ហាញខ្លួន ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចស្នើសុំឱ្យកងកម្លាំងសាធារណៈបង្ខំឱ្យសាក្សីរូបនោះបង្ហាញ ខ្លួនចំពោះមុខខ្លួនបាន ប៉ុន្តែមិនមែនដីកាបង្គាប់ឱ្យនាំខ្លួននោះទេ គឺជា **បញ្ជាឱ្យចូលមកបង្ហាញខ្លួន។** សិទ្ធិអំណាចនេះត្រូវបានផ្តល់ឱ្យដោយមាត្រា១៥៣ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

### ៣.១.៣ ដីកាបង្គាប់ឱ្យចាប់ខ្លួន

បើយើងនិយាយទៅដល់ពាក្យថាចាប់ខ្លួនគឺមានន័យថាជននោះបានប្រព្រឹត្តអំពើមួយ ដែលខុស ឆ្គងយ៉ាងខ្លាំងទៅនឹងដំណើរការនៃនីតិវិធី ពោលគឺជននោះពិតជាមានតម្រុយនៃ ពិរុទ្ធភាពយ៉ាងខ្លាំងក្លានឹងស៊ីសង្វាក់ទៅនឹងបទល្មើសដែលបានប្រព្រឹត្តទៅលើជនរងគ្រោះ។ ពេលខ្លះចៅក្រមស៊ើបសួរមិនចាំបាច់ចេញដីកាបង្គាប់ឱ្យនាំខ្លួន ក៏បានដែរ ប្រសិនបើមិនអាចកំណត់បានអត្តសញ្ញាណជនណាម្នាក់ ឬមិនដឹងថាជននោះស្ថិតនៅទីកន្លែងណា និងដើម្បីជាប្រយោជន៍ដល់ពេលវេលានៃកិច្ចនីតិវិធី។

ដីកាបង្គាប់ឱ្យចាប់ខ្លួននេះគឺជាបញ្ជាដល់កងកម្លាំងសាធារណៈ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនទាំងឡាយ ឱ្យចាប់ និងធ្វើការឃុំខ្លួនបុគ្គលដែលចាប់បាន។

ជាធម្មតាចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួន [36] ចំពោះដីកានេះដែរអាចត្រូវចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពីពិរុទ្ធភាព។ មួយវិញទៀតចៅក្រមស៊ើបសួរ និងអាចចេញដីកាបង្គាប់ឱ្យ ចាប់ខ្លួនបានលុះត្រាតែ៖

- បទល្មើសដែលចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬបទមជ្ឈឹម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។
- បុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួនមិនដឹងជាស្ថិតនៅទីណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

[36] មាត្រា១៩៦ នៃនីតិវិធីព្រហ្មទណ្ឌ

ព្រះរាជអាជ្ញា ក៏មានតួនាទីយ៉ាងសំខាន់នៅពេលចេញដីកាឱ្យចាប់ខ្លួននេះផងដែរ ពោលគឺមុននឹង ឈានដល់ការបង្គាប់ឱ្យចាប់ជនណាមួយនោះ ចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ ពីសំណាក់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានថែងអំពីមូលហេតុ ក្រោយពីបានទទួលយោបល់ពីសំណាក់ព្រះរាជអាជ្ញា។ យោបល់របស់ព្រះរាជអាជ្ញានេះមិនចងកាតព្វកិច្ចចំពោះការចេញដីកាឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរឡើយ ប្រសិនបើព្រះរាជអាជ្ញាសំណូមពរមិនឱ្យចេញដីកាបង្គាប់ឱ្យចាប់ខ្លួននេះក៏ដោយ ក៏ចៅក្រមស៊ើបសួរនៅតែចេញដីកានេះបានដដែល ក៏ប៉ុន្តែបើព្រះរាជអាជ្ញាមិនសុខចិត្តអាចប្ដឹងទៅសភាស៊ើបសួរបានដែលជានាយឋានានុក្រមរបស់ចៅក្រមស៊ើបសួរ។ចំពោះការផ្សព្វផ្សាយអំពីដីកានេះ គឺព្រះរាជអាជ្ញាជាអ្នករ៉ាប់រង និងព្យាយាមផ្សព្វផ្សាយ[37]ឱ្យបានទូលំទូលាយ។

ក្នុងករណីចាំបាច់ដីកាបង្គាប់ឱ្យចាប់ខ្លួន អាចផ្សព្វផ្សាយ ជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានាដែលមានប្រសិទ្ធភាពក្នុងការចាប់ខ្លួន។

**៣.១.៣.១ ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន**

ដីកាបង្គាប់ឱ្យចាប់ខ្លួនមានតួនាទីដូចជា ស្វែងរក ចាប់ខ្លួន និងឃុំខ្លួន។

ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌[38] ដែលមានកាតព្វកិច្ច ស្វែងរក ចាប់ខ្លួន និងនាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ហើយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលនោះ។ បុគ្គលដែលពាក់ព័ន្ធត្រូវតែបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន។ ក្នុងករណីដែលពុំអាចធ្វើដូច្នេះបាន បុគ្គលដែលពាក់ព័ន្ធ ត្រូវបានសួរចម្លើយដោយព្រះរាជអាជ្ញានៅកន្លែងឃុំខ្លួន ហើយព្រះរាជអាជ្ញាត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរនូវកំណត់ហេតុសួរចម្លើយនោះ។

ដូចគ្នានឹងការប្រតិបត្តិដីកាបង្គាប់ឱ្យនាំខ្លួនដែរ ប្រការដែលត្រូវជៀសវាងដាច់ខាត ដើម្បីកុំឱ្យមានការរំលោភសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិធម៌ដែលអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន មិនអាចចូលទៅក្នុងលំនៅដ្ឋាន របស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង៦ ព្រឹក និងក្រោយម៉ោង១៨ល្ងាចបានទេ។

ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួន។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកា ឬ ចុងដីកា ដែលបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើម។ បុគ្គលដែលពាក់ព័ន្ធត្រូវតែបានគេនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ អង្គការអយ្យការត្រូវចាត់ចែងចំពោះការ

[37] មាត្រា១៩៧ នៃនីតិវិធីព្រហ្មទណ្ឌ

[38] មាត្រា១៩៩ នៃនីតិវិធីព្រហ្មទណ្ឌ

ផ្ទេរបុគ្គលដែលពាក់ព័ន្ធទៅពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនមួយផ្សេងទៀត។ ចំពោះករណីដែលបុគ្គលដែលពាក់ព័ន្ធនោះមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួនទេនោះ បុគ្គលនេះត្រូវបានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ។ ហើយព្រះរាជអាជ្ញានោះ ត្រូវធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។

ក្នុងករណីនេះ បុគ្គលដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួននោះ ចិរវេលានៃការឃុំខ្លួន ត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។

**៣.១.៤ ការឃុំខ្លួនបណ្តោះអាសន្ន**

ក្នុងករណីមួយនៅពេលដែលជាលក្ខខណ្ឌចាំបាច់ ដើម្បីកុំឱ្យមានការចលាចលដែលកើតឡើងដោយសារបទល្មើសដែលទើបនឹងកើតឡើងរួច ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យឃុំខ្លួនជននោះជាបណ្តោះអាសន្នដើម្បីជាប្រយោជន៍ដល់ភាគីទាំងអស់ដែលនៅក្នុងរឿងព្រហ្មទណ្ឌនោះពីព្រោះថាបើមិនធ្វើដូច្នេះទេអាចនឹងមានរឿងកើតឡើងដែលជាផលលំបាកដូចជាមានការគាប់សង្កត់ទៅលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬបណ្តាលឱ្យមានគុំនុំគុំគួន នាំឱ្យមានការសងសឹកគ្នាទៅវិញទៅមកជាដើម។តែបើយោងទៅតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ គេបានចែងថា ជនត្រូវចោទត្រូវតែមានសេរីភាព [39] ប៉ុន្តែក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្នប្រសិនបើ ជនត្រូវចោទនោះបានបំពេញនូវលក្ខខណ្ឌ មួយចំនួនដែលជាមូលហេតុចាំបាច់ដែលត្រូវ តែឃុំខ្លួនជននោះ កុំឱ្យមានភាពរីករាលដោយសារអង្គហេតុដែលបានកើតឡើងព្រោះតែបទល្មើស។

**៣.១.៤.១ ករណីនៃការឃុំខ្លួនបណ្តោះអាសន្ន**

ជាទូទៅការឃុំខ្លួនបណ្តោះអាសន្នអាចប្រព្រឹត្តទៅបានគឺទាល់តែក្នុងករណីការចោទប្រកាន់ទាំងឡាយ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់បានកំណត់ផន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពីមួយឆ្នាំ[40]។ **ឧទាហរណ៍** ដូចជាបទល្មើសឃាតកម្ម បទល្មើសហិង្សាដោយចេតនាជាដើម។ ចំណែក ឯបទល្មើសលហុ វិញគឺមិនតម្រូវឱ្យ មានការឃុំខ្លួនបណ្តោះអាសន្នឡើយ ពីព្រោះថាយើងសុទ្ធតែដឹងហើយ បទល្មើសលហុ មានការផន្ទាទោស ដាក់ពន្ធនាគារត្រឹមតែក្រោម ឬស្មើ៦ថ្ងៃតែប៉ុណ្ណោះ (មានន័យថាទោះបីជាការផន្ទាទោស ត្រឹមតែមួយ ម៉ោងក៏ដោយ ក៏បទល្មើសនោះជាបទលហុដែរប្រសិនបើមានបទល្មើសណាមួយផន្ទាទោសបែបនេះ) អញ្ចឹងហើយទើបការឃុំខ្លួនក្នុងបទលហុមិនអាចប្រព្រឹត្តទៅបានឡើយ ព្រោះមិនគ្រប់លក្ខខណ្ឌនៃមាត្រា ២០៤ បានកំណត់។

[39] មាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[40] មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ៣.១.៤.២ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

បន្ថែមទៅលើមាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការឃុំខ្លួនបណ្តោះអាសន្ន អាចត្រូវបានបង្គាប់ ឱ្យឃុំបានលុះត្រាតែបានបំពេញដែលជាលក្ខខណ្ឌ[41]ចាំបាច់មួយចំនួនទៀត ដែលលក្ខខណ្ឌទាំងអស់នោះមានដូចតទៅៈ

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតឡើងជាថ្មី
- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
- ដើម្បីរក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ
- ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

### ៣.១.៤.៣ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានបែងចែកតាមចំណាត់ថ្នាក់នៃបទល្មើស ជាបីសណ្ឋានគឺៈ

- **ការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ជាអាទិ៍**

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើសពី ១ឆ្នាំ បានទេចំពោះបទល្មើសនីមួយៗ ប៉ុន្តែអាចពន្យារពេលបានពីរដង ដោយក្នុងមួយដងៗមានថិរវេលា១ឆ្នាំ(សរុបទាំងអស់បីឆ្នាំ)[42]។

- **ការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋ**

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទឧក្រិដ្ឋ ត្រូវបានបែងចែកជាបីផ្នែក តាមនីតិភាពនៃ បុគ្គលដែលរងការចោទប្រកាន់ដូចខាងក្រោមៈ

១. នីតិជន ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ខែ បានទេ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារពេលបានពីរដង ដោយក្នុងមួយដងៗមានថិរវេលា ៦ខែ (សរុប១៨ខែ)។

២. អនីតិជន អាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ខែ បានទេ កាលបើផុតថិរវេលានេះចៅក្រមស៊ើបសួរមិនអាចពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នបានទៀតឡើយ។

៣. អនីតិជន អាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ខែ បានទេ កាលបើផុតថិរេលានេះចៅក្រមស៊ើបសួរមិនអាចពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នបានឡើយ។

[41] មាត្រា២០៥ នៃក្រមនីតិវីធីព្រហ្មទណ្ឌ

[42] មាត្រា២១០ នៃក្រមនីតិវីធីព្រហ្មទណ្ឌ

- **ការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិម**

ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីបទមជ្ឈិម ក៏ត្រូវបានបែងចែកជាបីផ្នែកផងដែរ តាមនីតិភាពនៃបុគ្គលដែលរងការចោទប្រកាន់ដូចខាងក្រោម៖

១. នីតិជន ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ខែ បានទេ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារពេលបានម្ដងគត់ ដោយមានចិរវេលាមិនឱ្យលើសពី ២ខែ បានឡើយ(សរុប៨ខែ)។

២. អនីតិជន អាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ខែបានទេ កាលបើផុតចិរវេលានេះ ចៅក្រមស៊ើបសួរមិនអាចពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្នបានទៀតឡើយ។

៣. អនីតិជន អាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ខែ បានទេ កាលបើផុតចិរវេលានេះ ចៅក្រមស៊ើបសួរមិនអាចពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្នបានទៀតឡើយ។

ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នទាំងបីចំណុចនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់ នីតិជន និង អនីតិជននោះឡើយ។

ជាងនេះទៅទៀតយើងសង្កេតឃើញថា អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នបានទេ។

### ៣.១.៤.៤ ដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកានេះ គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន[43]ដែលត្រូវតែឱ្យទទួល និងឃុំខ្លួនជនត្រូវចោទរហូតទាល់តែបានទទួលដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។ ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែមានសេចក្ដីសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នជាមុនសិន ហើយអាចបង្គាប់ឱ្យឃុំខ្លួនបុគ្គលណាម្នាក់បាន លុះត្រាតែជនត្រូវចោទនោះជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នតែប៉ុណ្ណោះ។ ត្រង់ចំណុចនេះយើងសង្កេតឃើញថា ចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបុគ្គលណាម្នាក់ ដោយមិនមានដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននោះឡើយ។

### ៣.១.៤.៥ ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ

ប្រសិនបើមានការធូរស្រាលពីស្ថានភាពរឹករវដែលកើតចេញពីបទល្មើស ឬដោយមានការស្នើសុំពីសំណាក់ជនត្រូវចោទ ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ អាចសម្រេចដោះលែងជនត្រូវចោទដែលកំពុងជាប់ឃុំឱ្យមានសេរីភាពវិញបាន ដោយឆន្ទានុសិទ្ធរបស់ខ្លួន។ តែនៅពេលដែលចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួររូបនេះអាច សម្រេចដាក់ជនត្រូវចោទដដែលនេះ ដោយដាក់ជននេះឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន ដោយអនុលោមតាមផ្នែកទី៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានកំណត់អំពីការត្រួត

[43] មាត្រា២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ពិនិត្យតាម ផ្លូវតុលាការ។ មិនតែប៉ុណ្ណោះចៅក្រមស៊ើបសួរខ្លួនឯងផ្ទាល់ក៏អាចដោះលែងជនត្រូវចោទនោះឱ្យនៅក្រៅឃុំដោយឯកឯងបាន ដែរបើទោះបីជាគ្មានការស្នើសុំពីសំណាក់ជនត្រូវចោទ ឬក៏ព្រះរាជអាជ្ញាក៏ដោយ។

**៣.១.៥ ការត្រួតពិនិត្យតាមផ្លូវតុលាការ**

ជាធម្មតានៅពេលដែលជនត្រូវចោទ បានឈានទៅដល់ដំណាក់កាលរបស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរ អាចសម្រេចថាឃុំខ្លួនជននោះ ឬ សម្រេចដាក់ជននោះឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលវិធានការណ៍ នៃការដាក់ឱ្យត្រួតពិនិត្យតាមផ្លូវតុលាការនេះដែរ គឺបានកម្រិតសិទ្ធិរបស់ជនត្រូវចោទឱ្យនៅក្រោមការបង្គាប់របស់ ចៅក្រមស៊ើបសួរ ដែលការហាមប្រាមចំនួន**១២ ចំណុច**[44] ។ ចំពោះវិធានការណ៍ នៃការត្រួតពិនិត្យតាមផ្លូវតុលាការនេះដែរ គឺមានលក្ខណៈ រាងធូរស្រាលជាង ការឃុំខ្លួនបណ្តោះអាសន្ន ពីព្រោះថាវិធានការណ៍នេះគឺ បានផ្តល់នូវសេរីភាពជូនជនត្រូវចោទ ឱ្យនៅក្រៅឃុំ ប៉ុន្តែត្រូវគោរពទៅតាម ចៅក្រមស៊ើបសួរបានកំណត់ចំពោះជននោះ។ ប៉ុន្តែ ប្រសិនបើជនត្រូវចោទនោះមិនគោរពទៅតាមអ្វីដែលចៅក្រមស៊ើបសួរបានកំណត់នោះទេ នោះចៅក្រមស៊ើបសួរ អាចសម្រេចឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទនោះបានដោយឆន្ទានុសិទ្ធរបស់ខ្លួនផ្ទាល់។

**៣.១.៥.១ ដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

ចៅក្រមស៊ើបសួរដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយតាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន ឬ តាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា។ ដោយចៅក្រមស៊ើបសួរត្រូវចេញដីកាបញ្ជាក់នៅក្នុងដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលជាសេចក្តីសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។ ហើយដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[45]។

ការត្រួតពិនិត្យតាមផ្លូវតុលាការនេះផងដែរ យើងសង្កេតឃើញថា ព្រះរាជអាជ្ញាក៏អាចធ្វើសេចក្តីសន្និដ្ឋានសុំឱ្យដាក់ខ្លួនជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាកាបានផងដែរ។ ប៉ុន្តែសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាអាចត្រូវបានចៅក្រមស៊ើបសួរ បដិសេធចំពោះពាក្យសុំនោះបាន ដោយចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធការសុំនេះក្នុងរយៈពេល ៥ ថ្ងៃ។ ជាងនេះទៅទៀតយើងមើលឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុវត្តនៅពេលបច្ចុប្បន្ននេះ ត្រង់មាត្រា២២៦ មិនបានកំណត់ថា រយៈពេលណាមួយច្បាស់លាស់ដែលចៅក្រមស៊ើបសួរត្រូវជូនដំណឹងនូវសេចក្តីសម្រេចបដិសេធការស្នើសុំរបស់ព្រះរាជអាជ្ញានោះទេ ដោយគ្រាន់តែបញ្ជាក់ថា ចៅក្រមស៊ើបសួរត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញាចំពោះដីកាសម្រេចរបស់ខ្លួន។ ដោយឡែក

[44] មាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[45] មាត្រា២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃ នោះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលដែលមានសមត្ថកិច្ចសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ៣.១.៥.២ ភាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចសម្រេចដាក់ជនត្រូវចោទទាំងឡាយ ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជននោះត្រូវបានចោទប្រកាន់ អំពីបទល្មើស ដែលត្រូវផន្ទាទោស ដាក់ពន្ធនាគារ។

ការត្រួតពិនិត្យតាមផ្លូវតុលាការនេះទៀតសោត គឺមានអានុភាពបង្គាប់ឱ្យជនត្រូវចោទដែល នៅក្រៅឃុំ ឱ្យគោរពទៅតាមលក្ខខណ្ឌដែលមានដូចខាងក្រោម៖

១. មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីដែលចៅក្រមស៊ើបសួរបានកំណត់

២. មិនត្រូវប្តូរលំនៅដ្ឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ

៣. មិនត្រូវទៅកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ

៤.ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រម ស៊ើបសួរ

៥. ត្រូវឆ្លើយតបនឹងការ កោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៦. ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ

៧. មិនត្រូវបើកបររថយន្ត

៨. មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

៩. ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ

១០. មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធនានា ហើយត្រូវប្រគល់ជូននូវអាវុធទាំងនោះដល់ការិយាល័យ ក្រឡាបញ្ជី

១១. ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងស្ថិតក្រោមការព្យាបាលក្នុងមន្ទីរពេទ្យ

១២. មិនត្រូវប្រកបធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះៗ

ជាអញ្ញាត្រកម្ម [46] អនីតិជនអាយុតិចជាង១៨ឆ្នាំមិនអាចត្រូវដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាម ផ្លូវតុលាការទេ ពីព្រោះថាមិនទាន់ដល់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។

[46] អញ្ញាត្រកម្ម គឺជាករណីលើកលែង

**៣.១.៥.៣ ការប្រគល់ប្រកាន់ដៃដល់ជនត្រូវចោទ**

នៅក្នុងករណីដូចដែលបានបកស្រាយចំនួន១២ ចំណុចខាងលើនេះ ចំណុចទី៦ ទី៩ និងទី១០ ជនត្រូវចោទ ត្រូវទទួលបង្កាន់ដៃស្តីពីការប្រគល់ឯកសារអត្តសញ្ញាណ ប្រាក់ធានា ឬអាវុធ និងត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី [47] ។ បង្កាន់ដៃបង់ប្រាក់ធានា ឬអាវុធ ត្រូវចុះហត្ថលេខារួមដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ។

ប្រាក់ធានា និងអាវុធត្រូវតម្កល់ទុកនៅ គណនីពិសេសដែលបើកនៅធានាគារ ឬត្រូវរក្សាទុកនៅ ទីកន្លែងមួយដែលមានការធានាសន្តិសុខរឹងមាំ។ ទីកន្លែងនេះត្រូវជ្រើសរើសតាមការឯកភាពគ្នា ដោយប្រធានតុលាការនិងព្រះរាជអាជ្ញា។

**៣.១.៥.៤ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ ដោយព្រះរាជអាជ្ញា ឬជនត្រូវចោទ**

ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា[48] ហើយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការផងដែរ។

ព្រះរាជអាជ្ញា ក៏អាចសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបាននៅគ្រប់ពេលវេលាទាំងអស់ ហើយចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ថ្ងៃ។ បើសិនជារយៈពេល ៥ថ្ងៃនេះកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច នោះព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលមានសមត្ថកិច្ចសម្រេចជំនួសចៅក្រមស៊ើបសួរវិញ។

ចំពោះជនត្រូវចោទវិញក៏អាចដាក់ពាក្យសុំលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ចៅក្រមស៊ើបសួរ ត្រូវបញ្ជូនពាក្យសុំរបស់ជនត្រូវចោទ និងសំណុំរឿងនោះភ្លាម ទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យនឹងផ្តល់យោបល់។ ចៅក្រមក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ថ្ងៃ បន្ទាប់ពីបញ្ជូនសំណុំរឿងនោះទៅព្រះរាជអាជ្ញា។ ពាក្យសុំរបស់ជនត្រូវចោទនេះវាមានលក្ខណៈខុសគ្នានឹងការស្នើសុំរបស់ព្រះរាជអាជ្ញាត្រង់ថា កាលណាមានពាក្យសុំឱ្យលើកលែង ឬឱ្យកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការនេះ បានធ្វើជាថ្មីមុនពេលចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំលើកមុន នោះរយៈពេល ៥ថ្ងៃនេះ ត្រូវចាប់ផ្តើមគិតពីពេលចេញសេចក្តីសម្រេចលើពាក្យសុំមុន។ ដីកាសម្រេចបដិសេធនឹងពាក្យសុំត្រូវតែមានសំអាងហេតុ។ បើសិនជារយៈពេល៥ថ្ងៃនេះបានកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ។

---

[47] មាត្រា២២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[48] មាត្រា២២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលសម្រេចតាមឆន្ទានុសិទ្ធិ តាមពាក្យសុំរបស់ព្រះរាជអាជ្ញា ឬរបស់ជនត្រូវចោទនេះ ត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

**៣.១.៥.៥ ការគេចវេសពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**

ប្រសិនបើជនត្រូវចោទ បានគេចវេស [49] ដោយចេតនាពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នបាន ទោះក្នុងករណីដែល៖

- ទោសជាប់ពន្ធនាគារដែលត្រូវរងនោះ មានថិរវេលាប៉ុន្មានក៏ដោយ (**មានន័យថាលក្ខខណ្ឌនៃមាត្រា ២០៤ លែងជាឧបសគ្គនៃការឃុំខ្លួនបណ្តោះអាសន្នទៀតហើយ**)
- ជនត្រូវចោទ ត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមានៃថិរវេលានៃការឃុំខ្លួនបណ្តោះសន្ន តាមមាត្រា ២០៨ ២០៩ ២៩០ ២១៣ និង២១៤ ក៏ដោយ។

កាលណាសម្រេចថា នឹងឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ ហើយត្រូវឱ្យមេធាវីជូនមធ្យោបាយការពារ បើសិនជាមានមេធាវីអមផងនោះ។

ដីកាសម្រេចត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

ការឃុំខ្លួនបណ្តោះអាសន្នដែលសម្រេចតាមមាត្រា ២៣០ នៃនីតិវិធីព្រហ្មទណ្ឌនេះ មិនអាចឱ្យលើសពី ៤ ខែ ចំពោះនីតិជន និងមិនអាចលើសពី ២ខែ ចំពោះអនីតិជនឡើយ។

ការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបានបញ្ចប់នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ។ ប៉ុន្តែ តាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចសម្រេចរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ **យោងតាមមាត្រា ២៤៩ កថាខណ្ឌទី៤ និងទី៦**

ម៉្យាងទៀតការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏ត្រូវបញ្ចប់នៅពេលដែលតុលាការប្រកាសសាលក្រម[50] ។

[49] មាត្រា២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[50] មាត្រា ៣៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

# ជំពូកទី៤
# ការបិទការស៊ើបសួរ

# ជំពូកទី៤
# ការបិទការស៊ើបសួរ

## ៤.១ ដីកាដំណោះស្រាយ

កាលណាបើការស៊ើបសួរត្រូវបានចប់សព្វគ្រប់នោះ នៅក្នុងពេលនោះដែរ ចៅក្រមស៊ើបសួរត្រូវចេញនូវដីកាមួយ ដើម្បីសម្រេចថាត្រូវបញ្ជូនជននោះទៅជំនុំជម្រះ ឬធ្វើការលើកលែងការចោទប្រកាន់[51] ចំពោះជនត្រូវចោទនោះ ដែលដីកានេះដែរត្រូវបានគេឱ្យឈ្មោះថា ដីកាដំណោះស្រាយ។ ចំពោះដីកាដំណោះស្រាយ នេះទៀតសោត គឺមានអានុភាពបញ្ចប់នូវការឃុំខ្លួនបណ្ដោះអាសន្ន និងការដាក់ត្រួតពិនិត្យតាមផ្លូវតុលាការ ទាំងឡាយ ដើម្បីដោះលែងខ្លួនជននោះឱ្យមានសេរីភាព ដើម្បីយកជននោះទៅជំនុំជម្រះ ឬមានសេរីភាពពេញលេញ ប្រសិនបើ ចៅក្រមស៊ើបសួរសម្រេចលើកលែងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ចំពោះជនត្រូវចោទនោះ។ មិនតែប៉ុណ្ណោះនៅពេលចេញ ដីកាដំណោះស្រាយនេះដែរចៅក្រមស៊ើបសួរក៏ អាចសម្រេចប្រគល់វត្ថុដែល យកមកធ្វើជាវត្ថុតាង ទៅឱ្យម្ចាស់ដើមវិញ ប្រសិនបើគាត់យល់ឃើញថា វាគ្មានភាពស៊ីសង្វាក់ ទៅនឹងបទល្មើសដែល បានកើតឡើង។

បើចៅក្រមស៊ើបសួរ យល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជន នោះទៅតុលាការដើម្បីជំនុំជម្រះ ការបញ្ជូនទៅជំនុំជម្រះនេះដែរត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់បានកំណត់។ ប្រសិនជាគាត់សម្រេចបញ្ជូនជននោះទៅជំនុំជម្រះនៅក្នុងដីកាដំណោះស្រាយ នោះចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការដើម្បីកំណត់ពេលសវនាការ។

ផ្ទុយទៅវិញបើចៅក្រមស៊ើបសួររូបនេះសម្រេចលើកលែងការចោទប្រកាន់ទាល់តែមានករណីដូចតទៅៈ

- អំពើប្រព្រឹត្ត មិនមែនជាបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិម
- ជនល្មើសប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ
- ករណីដែលបណ្ដឹងអាជ្ញារលត់[52]។

ក្រោយពេលដែលដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរបានចូលជាស្ថាពរហើយ ប្រសិនបើមានភស្តុតាងដាក់បន្ទុកថ្មីបានផុះឡើង ការស៊ើបសួរអាចបើកឡើងវិញបាន តាមគំនិតផ្ដួចផ្ដើមរបស់ព្រះរាជអាជ្ញា។

[51] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[52] ច្បាប់ស្ដីវិសោធនកម្មមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៣

ដីកាដំណោះស្រាយជានិច្ចជាកាលត្រូវតែមានសំអាងហេតុ។ ចៅក្រមស៊ើបសួរ មិនត្រូវជាប់កាតព្វកិច្ចតាមដីកាស្ថាពររបស់ព្រះរាជអាជ្ញាទេ។

ដីកាដំណោះស្រាយនេះត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុត ដល់ភាគីទាំងឡាយនៅក្នុងរឿងក្តីព្រហ្មទណ្ឌនោះ។

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា មានសិទ្ធអាចប្តឹងរាល់សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរទាំងអស់ដែលបានសម្រេចនាដំណាក់កាលនៃការស៊ើបសួរ។ ជាងនេះទៅទៀត ដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា អាចប្តឹងទាស់ចំពោះដីកាដំណោះស្រាយ របស់ចៅក្រមស៊ើបសួរដែលបានសម្រេច បាន។

### ៤.១.១ ដីកាដំណោះស្រាយទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ននិងការត្រួតពិនិត្យតាម ផ្លូវតុលាការ

កាលណាចៅក្រមស៊ើបសួរសម្រេចក្នុងដីកាដំណោះស្រាយថាបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន នោះជននោះត្រូវដោះលែងឱ្យមានសេរីភាព។ ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃ ដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំដដែលក៏បានដែរ ពោលគឺនៅជាប់ឃុំរហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។

សេចក្តីសម្រេចរក្សាទុកជនត្រូវចោទក្នុងការឃុំខ្លួនជាបណ្តោះអាសន្នលែងមានអានុភាពក្នុងរយៈ ពេល៤ខែ។ប្រសិនបើជនត្រូវចោទមិនបានចូលខ្លួនទៅបង្ហាញមុខ នៅមុខតុលាការក្នុងរយៈ ពេល៤ខែនោះទេ ជនត្រូវចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង។

ដីកាដំណោះស្រាយនេះទៀតសោតត្រូវបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ[53]។

## ៤.២ ការបិទការស៊ើបសួរតាមបណ្តឹងសុំរបស់ភាគី

ដូចដែលបានរៀបរាប់ខាងលើនេះមកហើយថា ការសម្រេចបិតការស៊ើបសួរ ជានិច្ចការជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ប៉ុន្តែចិរវេលានៃការបិទការស៊ើបសួរនេះ ក្រមនីតិវិធីព្រហ្មទណ្ឌពុំមានចែងកំណត់ពេលណា មួយច្បាស់លាស់នោះទេ។ ដែលនាំឱ្យការស៊ើបសួររបស់ចៅក្រមស៊ើបសួរអាចមានរយៈពេលយូរ ហើយធ្វើឱ្យភាគីនៃរឿងក្តីរង់ចាំភាពយុត្តិធម៌តាមរយៈនៃការជំនុំជម្រះមានការអូសបន្លាយ។ ការដែលរឿងក្តីមួយត្រូវបានអូសបន្លាយរយៈពេលយូរហួសហេតុវានឹងក្លាយជាផលវិបាកដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិភាគីផងដែរ។ ហេតុផលនេះហើយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិនូវបទប្បញ្ញត្តិមួយចំនួនដែលអនុញ្ញាតឱ្យភាគីបានចូលរួមធ្វើសកម្មភាពក្នុងដំណើរការកិច្ចនីតិវិធីព្រហ្មទណ្ឌ ដើម្បីបញ្ចៀសភាពអសកម្មនៃកិច្ចនីតិវិធីស៊ើបសួរ។

[53] មាត្រា ២៤៩ កថាខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ភាគីនៃរឿងក្តីព្រហ្មទណ្ឌ ជាអាទិ៍ ជនត្រូវចោទនឹងដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិធ្វើពាក្យស្នើសុំឱ្យចៅក្រមស៊ើបសួរបញ្ឈប់ការស៊ើបសួរបាន[54]៖

- នៅពេលផុតថិរវេលា ១ឆ្នាំ គិតពីថ្ងៃចោទប្រកាន់ ជនត្រូវចោទអាចសុំឱ្យបិទការស៊ើបសួរ។
- នៅពេលផុតថិរវេលា ១ឆ្នាំ គិតពីថ្ងៃតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឱ្យបិទការស៊ើបសួរ។

ក្នុងរយៈពេលមួយខែ គិតពីថ្ងៃទទួលពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវតែសម្រេច។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចនៅក្នុងរយៈពេលនេះទេ អ្នកស្នើសុំអាចប្តឹងទៅប្រធានសភាស៊ើបសួរដែលធ្វើអធិបញ្ញាឱ្យចៅក្រមស៊ើបសួរសម្រេច។

ពាក្យសុំឱ្យបិទការស៊ើបសួរ អាចត្រូវធ្វើឡើងដោយមេធាវី។

## ៤.៣ មោឃភាពនៃកិច្ចនីតិវិធី

ជាទូទៅនៅគ្រប់សកម្មភាព នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួររាល់ភាគី ក្នុងរឿងក្តីព្រហ្មទណ្ឌ អាចប្តឹងទាមទារសុំមោឃភាពបាន ប្រសិនបើរាល់ភាគី មិនមានការពេញចិត្តចំពោះ កំណាត់ហេតុណាមួយ ដែលអនុវត្តនៅក្នុងកិច្ចនីតិវិធីនៃដំណាក់កាលចៅក្រមស៊ើបសួរបាន។ មិនតែប៉ុណ្ណោះសូម្បីតែចៅក្រមស៊ើបសួរ ខ្លួនឯងផ្ទាល់ក៏អាចធ្វើពាក្យស្នើសុំ ដើម្បីសុំមោឃភាពបានផងដែរ ប្រសិនបើគាត់យល់ឃើញថាមាន ចន្លោះប្រហោងនានា ដែលកើតមានឡើងនៅក្រោមការគ្រាប់គ្រងរបស់គាត់។

មួយវិញទៀត ក៏មានពាក្យប្តឹងខ្លះមិនអាចទទួលយកបាន[55]ដែរប្រសិនបើ៖

- ពាក្យប្តឹងគ្មានសំអាងហេតុ
- ពាក្យប្តឹងសុំទាក់ទងនឹងដីកាដែលអាចប្តឹងឧទ្ធរណ៍បាន
- ពាក្យប្តឹងសុំគ្មានមូលកភាពយ៉ាងជាក់ស្តែង។

សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ កាលណាពាក្យប្តឹងសុំត្រូវបានប្រកាសមិនទទួលយក សំណុំរឿងត្រូវបង្វិលភ្លាមទៅចៅក្រមស៊ើបសួរនោះវិញ។

### ៤.៣.១ អានុភាពនៃមោឃកម្ម

កាលណាបើសេចក្តីសម្រេចរបស់សភាស៊ើបសួរ សម្រេចថាទទួលយកពាក្យប្តឹងសុំមោឃភាព នោះអានុភាពនៃមោឃកម្ម[56] ត្រូវកើតឡើងភ្លាម។ ក្រោយពីទទួលពាក្យប្តឹងសុំមោឃកម្ម ចំពោះកិច្ច ឬលិខិតណាមួយនៃនីតិវិធី

---

[54] មាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[55] មាត្រា ២៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[56] មោឃកម្ម គឺជាការសម្រេចលុបចោលនូវកិច្ច ឬកំណត់ហេតុណាមួយនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ

ប្រសិនបើសភាស៊ើបសួរយល់ព្រមតាមពាក្យប្តឹងសុំនេះ សភាស៊ើបសួរត្រូវសម្រេចថា តើមោឃកម្មនេះ ត្រូវធ្វើទៅលើកិច្ច ឬលិខិតផ្សេងទៀតដែរឬទេ។

ចំពោះកិច្ច ឬលិខិតដែលត្រូវចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។

ថ្វីត្បិតតែពាក្យសុំមោឃកម្មត្រូវបានសម្រេចអនុញ្ញាតដោយសភាស៊ើបសួរក៏ដោយ ផលវិបាក[57] គឺនៅតែបន្តមាន ក្នុងនោះមានដូចជា៖

- ត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ
- ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត
- បន្តស៊ើបសួរដោយខ្លួនឯងលើរឿងនោះ (សភាស៊ើបសួរ)។

## ៤.៤ បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ

ដូចដែលបានបញ្ជាក់ខាងដើមមានតែដីកាសម្រេចទេ ដែលអាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បាន ដីកាបង្គាប់ចេញដោយចៅក្រមស៊ើបសួរពុំអាចឱ្យគេប្តឹងឧទ្ធរណ៍បានឡើយ។ ប៉ុន្តែសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ត្រូវបានកម្រិតចំពោះជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់[58] របស់ចៅក្រមស៊ើបសួរបាន។

ប៉ុន្តែចំពោះជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍បានតែចំពោះដីកាសម្រេចដែលមានដូចតទៅ៖

ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍បានចំពោះដីកា[59]ដូចតទៅ៖

- ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ
- ដីកាមិនព្រមប្រគល់វត្ថុដែលចាប់ឱ្យទៅម្ចាស់ដើមវិញ
- ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យ
- ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬ សុំឱ្យធ្វើប្រតិកោសលវិច័យ
- ដីកាស្តីពីរឿងឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ។

[57] មាត្រា ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[58] មាត្រា ២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[59] មាត្រា ២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ចំណែកឯដើមបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងឧទ្ធរណ៍ចំពោះដីកា[60]ដូចជា៖

- ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ
- ដីកាមិនព្រមស៊ើបសួរ
- ដីកាកំណត់ចំនួនប្រាក់កក់
- ដីកាប្រកាសមិនទទួលពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី
- ដីកាផ្ដន្ទាទោសដើមបណ្ដឹងរដ្ឋប្បវេណី
- ដីកាមិនព្រមប្រគល់សងវត្ថុដែលចាប់យកទៅម្ចាស់ដើមវិញ
- ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យ
- ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬ សុំឱ្យធ្វើប្រតិកោសលវិច័យ[61]
- ដីកាដំណោះស្រាយ។

យោងតាមការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចប្ដឹងឧទ្ធរណ៍ចំពោះដីកាស្ដីពីរឿងឃុំខ្លួនបណ្ដោះអាសន្នទាក់ទងទៅនឹងជនត្រូវចោទបាននោះទេព្រោះថាដីកានេះមិនត្រូវបានរៀបរាប់នៅក្នុងមាត្រា២៦៨។ ចំណែកឯជនត្រូវចោទវិញនោះក៏មិនអាចប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ ដូចដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ព្រោះថាដីកានេះមិនត្រូវបានរៀបរាប់នៅក្នុងមាត្រា២៦៨ និងមាត្រា២៦៧។

ក្រៅពីនេះ បុគ្គលដែលពាក់ព័ន្ធនឹងនីតិវិធីព្រហ្មទណ្ឌទាក់ទងនឹងការចាប់យកវត្ថុ ក៏មានសិទ្ធិប្ដឹងឧទ្ធរណ៍ផងដែរ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនព្រមប្រគល់វត្ថុដែលខ្លួនស្នើសុំឱ្យប្រគល់ឱ្យខ្លួនវិញ។

ចំពោះរយៈពេលនៃការប្ដឹងឧទ្ធរណ៍[62] វិញនោះគឺ៖

- ១ ខែ គិតពីពេលប្រកាសដីកា សម្រាប់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។
- ៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកា សម្រាប់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងជនសុំឱ្យប្រគល់វត្ថុចាប់យកឱ្យខ្លួនវិញ។

ការដាក់ពាក្យប្ដឹងឧទ្ធរណ៍ ត្រូវធ្វើនៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង។ កាលណាបានទទួលបណ្ដឹងឧទ្ធរណ៍ ក្រឡាបញ្ជីជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរ[63] ។ ក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរ ត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ ដោយមានសេចក្ដីចម្លងនៃលិខិតប្ដឹងឧទ្ធរណ៍ទៅការិយាល័យក្រឡាបញ្ជីនៃ

[60] មាត្រា ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[61] ប្រតិកោសលវិច្ច័យ គឺជាការធ្វើកោសលវិច្ច័យបន្ថែមទៅលើក្នុងរឿងក្ដីដដែល

[62] មាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[63] មាត្រា ២៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សភាស៊ើបសួរ ក្នុងរយៈពេល ៥ថ្ងៃ បន្ទាប់ពីមានបណ្ដឹងឧទ្ធរណ៍ លើកលែងតែក្នុងកាលៈទេសៈដែលមិនអាចជនៈបាន[64] ។

ការធ្វើពាក្យបណ្ដឹងឧទ្ធរណ៍ពុំនាំឱ្យនីតិវិធីនៃការស៊ើបសួរត្រូវផ្អាកនោះទេ លើកលែងតែបណ្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។ ប៉ុន្តែប្រធានសភាស៊ើបសួរអាចសម្រេចឱ្យផ្អាកនីតិវិធីនៃការស៊ើបសួរបានដែរ ចំពោះករណីខ្លះ។ សេចក្តីសម្រេចនេះមិនអាចប្ដឹងតវ៉ា[65]បានឡើយ ។

បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា អំពីដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ឬលើកលែងចោទប្រកាន់ជនត្រូវចោទដែលជាប់ឃុំ ជនត្រូវចោទនេះត្រូវរក្សានៅក្នុងពន្ធនាគារ រហូតដល់មានសេចក្តីសម្រេចពីសភាស៊ើបសួរ [66]។ ប្រសិនបើមានបណ្ដឹងឧទ្ធរណ៍អំពីដីកាលើកលែងចោទប្រកាន់ ហើយសភាស៊ើបសួរទទួលថាបណ្ដឹងឧទ្ធរណ៍[67]នេះមានភាពត្រឹមត្រូវ សភាស៊ើបសួរបន្តការស៊ើបសួរដោយខ្លួនឯងលើរឿងក្ដីនោះ។

[64] មាត្រា ២៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[65] មាត្រា ២៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[66] មាត្រា ២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[67] មាត្រា ២៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក អត្ថន័យនៃការស្រាវជ្រាវមួយនេះផ្តោតទៅលើដំណាក់កាលទីបីនៃរឿងព្រហ្មទណ្ឌដែលជាដំណាក់កាលមួយស្ថិតក្នុងអំណាចរបស់ចៅក្រមស៊ើបសួរ។ ក្នុងនាមជាចៅក្រមស៊ើបសួរដែលជាចៅក្រមអសនៈមានកាតព្វកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យ នឹងគោរពឱ្យបាន ម៉ឺងមាត់នូវក្រមសីលធម៌របស់ខ្លួន គឺមានន័យថា ចៅក្រមស៊ើបសួរត្រូវប្រកាន់ភ្ជាប់នូវឥរិយាបទអព្យាក្រឹត។ អ្វីដែលគួរឱ្យកត់សម្គាល់ ចំពោះសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ គឺកើតឡើងនៅពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងនៅពេលដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះជាដើម។ បើទោះជាយ៉ាងនេះក្តី ចៅក្រមស៊ើបសួរមិនអាចបើកការស៊ើបសួរតាមទំនើងចិត្តរបស់ខ្លួនបានឡើយប្រសិនបើគ្មានការចាត់តាំងពីប្រធានតុលាការ ដែលចង់បញ្ជាក់ថា មានតែប្រធានតុលាការទេជាអ្នកចាត់តាំងចៅក្រមស៊ើបសួរ ដើម្បីបំពេញមុខងារ ស៊ើបសួរទៅតាមវេននៃលំដាប់ចៅក្រមទាំងឡាយដែលអមសាលាជម្រះក្តីនោះ។ អ្វីដែលសំខាន់បំផុតនៅក្នុងដំណើរការនីតិវិធីនេះ ជាការស្រាវជ្រាវស្វែងរកការពិតនៃអង្គហេតុដែលជារឿងក្តីព្រហ្មទណ្ឌ ពោលគឺចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុក និង ដោះបន្ទុក ក៏ដូចជាធានាឱ្យបាននូវជំនឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋនៅក្នុងសង្គមទាំងមូលក្នុងការស្វែងរកយុត្តិធម៌ មានតម្លាភាព ធានាឱ្យបាននូវសមភាពក្នុងការទទួលការផ្តល់យុត្តិធម៌ ពីសំណាក់ស្ថាប័នតុលាការ។

កត្តាទាំងអស់នេះហើយ ដែលបានធ្វើឱ្យចៅក្រមស៊ើបសួរទទួលបានអំណាចពិសេសចំនួនពីរ ដូចជាអំណាចបង្ខំរបស់ចៅក្រមស៊ើបសួរ និង អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ។ អំណាចបង្ខំរបស់ចៅក្រមស៊ើបសួរ គឺចៅក្រមស៊ើបសួរមានអំណាចក្នុងការបញ្ជាឱ្យចូលខ្លួនចំពោះបុគ្គលដែលមិនព្រមឆ្លើយតបតាមការកោះហៅ។ អំណាចក្នុងការបញ្ជានេះផងដែល ជាអំណាចក្នុងការចេញដីកាព្រមទាំងការកេនកម្លាំងសារធារណៈដើម្បីអនុវត្តដីកានេះ។ ចំពោះអំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរវិញ យើងឃើញថាចៅក្រមស៊ើបសួរមានអំណាចច្រើនក្នុងការបង្ហាញភស្តុតាងដល់តុលាការ។ ចៅក្រមស៊ើបសួរប្រើប្រាស់អំណាចទាំងនេះដោយខ្លួនឯងផ្ទាល់ ឬ ប្រគល់អំណាចមួយចំនួនទៅឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត ឬ ដល់មន្ត្រីនគរបាលយុត្តិធម៌តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស នៅពេលដែលចៅក្រមស៊ើបសួរពុំមានលទ្ធភាពក្នុងការបំពេញកិច្ចស៊ើបសួរណាមួយ។ បន្ទាប់ពីចៅក្រមស៊ើបសួរ ពិនិត្យវាយតម្លៃដោយអធិបតេយ្យនូវតម្រុយនៃពិរុទ្ធភាពរបស់ជនល្មើស ភស្តុតាងដែលប្រមូលបាន និងលទ្ធភាពមួយដែលខ្លួនយល់ឃើញថាអាចបង្ហាញនូវការពិតបានហើយនោះ ចៅក្រមស៊ើបសួរនឹងសម្រេចបិទការស៊ើបសួរដោយអធិតេយ្យរបស់គាត់ ដោយចៅក្រមស៊ើបសួរខ្លួនឯងនឹងចេញដីកាមួយដើម្បីបញ្ជាក់អំពីការបញ្ចប់នៃកិច្ចស៊ើបសួររបស់ខ្លួន ដែលដីកានោះគឺហៅថា ដីកាដំណោះស្រាយ។

# អនុសាសន៍

ក្នុងឱកាសដើម្បីជាការផ្តល់គំនិតក្នុងគោលបំណងមួយ ដែលធ្វើយ៉ាងណាឱ្យប្រព័ន្ធនៃការស្រាវជ្រាវ និង សិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការស្វែងរកការពិតដោយប្រកាន់ភ្ជាប់នូវសុក្រឹត្យភាព តម្លាភាព សមភាព និងការធានាឱ្យមានការជឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ។ ជាពិសេសនោះធានានូវប្រសិទ្ធិភាព ភាពស្អាតស្អំ របស់ស្ថាប័នតុលាការ ដែលមានតួនាទីផ្តល់នូវសេវាយុត្តិធម៌ចំពោះវិវាទនៅក្នុងសង្គម។ ដូចដែលបានរៀបរាប់នៅ ក្នុងកិច្ចការស្រាវជ្រាវនេះរួចមកហើយថា ការសម្រេចបិទការស៊ើបសួរ ជានិច្ចកាលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើប សួរ ប៉ុន្តែថិរវេលានៃការស៊ើបសួរនេះ ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានចែងកំណត់ពេលវេលាណាមួយច្បាស់លាស់នោះ ទេ។ ជាក់ស្តែងនៅពេលមានវិវាទព្រហ្មទណ្ឌកើតឡើងភាគីរងគ្រោះ និងជនត្រូវចោទជាភាគីរងចាំការផ្តល់ភាព យុត្តិធម៌តាមរយៈគ្រប់ដំណាក់កាលនៃនីតិវិធី នៅក្នុងអំឡុងពេលមួយដែលសមរម្យ ព្រោះនៅពេលដំណើរការនៃរឿង ក្តីត្រូវបានអូសបន្លាយរយៈពេលយូរហួសហេតុវាជាផលវិបាកដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីផងដែរ។ ជា ពិសេសវិធានការឃុំខ្លួនបណ្តោះអាសន្ន ដែលស្ថិតនៅក្នុងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ ក្នុងការសម្រេចចំពោះ ជនត្រូវចោទ ដោយការអនុវត្តវិធាននេះគឺពិតណាស់បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរនូវ សិទ្ធិសេរីភាព របស់ជនត្រូវចោទនៅ ក្នុងរយៈពេលមួយដោយអាស្រ័យទៅលើបទល្មើស។

ប្រសិនបើរឿងក្តីមួយត្រូវបានចំណាយពេលវេលាយូរក្នុងការស្វែងរកយុត្តិធម៌នោះ គឺសបញ្ជាក់ឱ្យឃើញថា យុត្តិធម៌ប្រកបដោយភាពយឺតយ៉ាវស្មើនឹងអយុត្តិធម៌។ ហើយភាពយឺតយ៉ាវក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក និង ភស្តុតាងដោះបន្ទុក នេះជាភាពអសកម្មក្នុងការបំពេញនៃកិច្ចនីតិវិធីស៊ើបសួររបស់ចៅក្រមស៊ើបសួរផងដែរ។ ដោយ ឡែកក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិបទប្បញ្ញត្តិមួយចំនួនដែលអនុញ្ញាតឱ្យភាគីបានចូលរួមធ្វើសកម្មភាពក្នុង ដំណើរការកិច្ចនីតិវិធីព្រហ្មទណ្ឌ ដើម្បីបញ្ចៀសភាពអសកម្មនៃកិច្ចស៊ើបសួរដោយជនត្រូវចោទ និងដើមបណ្តឹងរដ្ឋ ប្បវេណីមានសិទ្ធិធ្វើពាក្យស្នើសុំឱ្យចៅក្រមស៊ើបសួរបញ្ឈប់ការស៊ើបសួរបាន ប៉ុន្តែត្រូវរងចាំឱ្យផុតថិរវេលា ១ឆ្នាំ សិន ដែលគិតចាប់ពីថ្ងៃចោទប្រកាន់ ឬថ្ងៃតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ហេតុនេះហើយរយៈពេលនៃដំណើរការកិច្ច នីតិវិធីស៊ើបសួរពិតជាមានសារៈសំខាន់ណាស់ព្រោះវាបានសម្រួលដល់ផលប្រយោជន៍របស់គូភាគីដូចជា ដើមប ណ្តឹងរដ្ឋប្បវេណីទទួលបានសំណងចំពោះព្យសនកម្ម ឬ ជនត្រូវចោទបានទទួលភាពស្អាតស្អំរបស់ខ្លួនមកវិញផង ដែរ។ ម្យ៉ាងទៀតនោះការពន្លឿនដំណើរការនៃកិច្ចស៊ើបសួរក៏បានសម្រួលដល់បញ្ហានៃការកកស្ទះសំណុំរឿងព្រហ្ម ទណ្ឌដែរ។

ជាចុងក្រោយការលើកឡើងក្នុងអនុសាសន៍ខាងលើរបស់យើងគឺមានគោលបំណងតែមួយគត់ គឺដើម្បីធ្វើ ឱ្យប្រព័ន្ធយុត្តាធិការស៊ើបសួររបស់ប្រទេសកម្ពុជាយើងមានគុណភាព ប្រសិទ្ធិភាព ដើម្បីជាទីទុកចិត្តរបស់ប្រជា

ពលរដ្ឋមកលើស្ថាប័នតុលាការដែលជាស្ថាប័នស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន និង គ្រប់ស្រទាប់វណ្ណៈ៕

# ឯកសារយោង និង ឯកសារពិគ្រោះ

# ឯកសារយោង និង ឯកសារពិគ្រោះ

## ១.បទដ្ឋានគតិយុត្តិ

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៣។

- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០០៧។

- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុថ្ងៃទី ៣១ ខែ វិច្ឆិកា ឆ្នាំ២០១០។

- ច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៣។

- ច្បាប់ស្ដីពីលក្ខន្តិកៈ ចៅក្រម និង ព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៤។

## ២. សៀវភៅ

- សៀវភៅ នីតិវិធីព្រហ្មទណ្ឌ របស់លោកសាស្រ្តាចារ្យ **រុន ពណ្ណារិទ្ធ** និង លោកស្រីសាស្រ្តាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ ២០១៥ - ២០១៦។

- សៀវភៅ នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយៈ លោកស្រី **ឌី លីឡា** និង លោក **ខាន់ សុខា** ។

# ឧបសម្ព័ន្ធ

17

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ ..........

លេខ ..........តព្រ.

## ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន

